# ផ្នែក ឃ

# ការបណ្ដុះបណ្ដាល
# អ្នកសម្របសម្រួលជាយុវជន

បុគ្គលិកអង្គការទស្សនៈពិភពលោក និងអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYCបណ្ដុះបណ្ដាលអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ដើម្បីជួយសម្របសម្រួលក្លឹប SNYC។ ប្រសិនបើអាច បុគ្គលិកអង្គការទស្សនៈពិភពលោកគួរបណ្ដុះបណ្ដាលអ្នកសម្របសម្រួលជាយុវជនទាំងនេះ ដោយប្រើប្រាស់សៀវភៅមគ្គុទេសសម្រាប់អ្នកសម្រួលក្លឹបយុវជននារីកឆ្លាត នៅក្នុងម៉ោងរៀនដែលមានរយៈពេលមួយថ្ងៃក្រោយពីអ្នកសម្របសម្រួល ជាយុវជនទាំងនោះត្រូវបានជ្រើសរើសរួច និងនៅមុនពេលក្លឹបចាប់ផ្ដើម។



# មេរៀនទី១០ ៖ ណែនាំអ្នកសម្របសម្រួលជាយុវជនឲ្យស្គាល់អំពីក្លឹប SNYC

## ទិស្ដបំណង

ដើម្បីជួយអ្នកចូលរួមឲ្យស្គាល់គ្នាទៅវិញទៅមក និងយល់ដឹងបន្ថែមទៀតអំពីក្លឹប SNYC។

## រយៈពេល

៦០ នាទី

## សម្ភារ

- ឯកសារចម្លងនៃសៀវភៅមគ្គុទេសសម្រាប់អ្នកសម្របសម្រួលក្លឹបយុវជននារីកវៃឆ្លាតអ្នកសម្របសម្រួលក្លឹប SNYC ជាយុវជនមិនទទួលបានសៀវភៅមគ្គុទេសសម្រាប់អ្នកសម្រួលក្លឹបយុវជននារីកវៃឆ្លាតនេះទេ
- ឯកសារចម្លងនៃប័ណ្ណព័ត៌មានលេខ ១០ក ៖ ល្បែងត្រៀមសម្រាប់ចាប់ផ្ដើម» សម្រាប់អ្នកចូលរួមនីមួយៗ
- ឯកសារយោង «ប័ណ្ណព័ត៌មានលេខ ១០ខ ៖ សំណួរល្បែងបោះបាល់ វំពុកមេរៀនវគ្គ១» បាល់ មួយ

## អ្នកចូលរួម

អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោក ឬអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ដែលបានបញ្ចប់ការបណ្ដុះបណ្ដាល អំពីឧបករណ៍នារីកវៃឆ្លាត និងការបណ្ដុះបណ្ដាលអំពីសៀវភៅមគ្គុទេសសម្រាប់អ្នកសម្របសម្រួលក្លឹបយុវជននារីកវៃឆ្លាត។

## សេចក្ដីផ្ដើម

ស្វាគមន៍ចំពោះក្រុម និងណែនាំខ្លួនឯង។ ចូរពន្យល់ថា មេរៀននេះនឹងជួយអ្នករាល់គ្នាឲ្យស្គាល់គ្នាទៅវិញទៅមកឲ្យយល់ដឹងអំពី ក្លឹបយុវជននាវិកវៃឆ្លាត (ដែលហៅថា SNYC) ហើយយល់ដឹងរបៀបធ្វើជាអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC។

## សកម្មភាពត្រៀមសម្រាប់ចាប់ផ្ដើម

សកម្មភាពនេះ នឹងជួយឲ្យអ្នកចូលរួមមានអារម្មណ៍ធូរស្រាលហើយស្គាល់ឈ្មោះគ្នាទៅវិញទៅមក។

ចែកច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ១០ ៖ ល្បែងត្រៀមសម្រាប់ចាប់ផ្ដើម» ឲ្យអ្នកចូលរួមនីមួយៗ ហើយឲ្យពួកគាត់មើលចំណុច «ល្បែងចងចាំឈ្មោះអ្នកចូលរួម»

ដោយអនុវត្តតាមសេចក្ដីណែនាំដើម្បីលេងល្បែងនេះជាមួយអ្នកចូលរួម។

## សេចក្ដីណែនាំ៖ តើក្លឹបយុវជនអ្នកតម្រង់ទិសឆ្លាតវៃ គឺជាអ្វី?

ចូរពន្យល់ថានៅឆ្នាំក្រោយពួកគាត់នឹងជួយសម្របសម្រួលក្លឹបយុវជននាវិកវៃឆ្លាត។ មុនពេលពន្យល់ថាតើក្លឹបនោះជាអ្វី ត្រូវពន្យល់ថា មានពាក្យថ្មីៗមួយចំនួនដែលត្រូវសិក្សា៖

### ក្លឹប SNYC

នេះគឺជាពាក្យបំព្រួញសម្រាប់ក្លឹបយុវជននាវិកវៃឆ្លាត។

### អ្នកសម្របសម្រួល

នេះគឺជាមនុស្សម្នាក់ដែលជួយដឹកនាំសកម្មភាពមួយ ដែលក្នុងករណីនេះគឺសកម្មភាពរបស់ ក្លឹប SNYC

### មេរៀន

នេះគឺជាមេរៀននៅក្នុងឧបករណ៍នាវិកវៃឆ្លាត ដែលមានទាំងអស់៣១មេរៀន។ ក្លឹបភាគច្រើនជួបជុំគ្នារាល់ពីរសប្ដាហ៍ម្ដងហើយត្រូវបញ្ចប់មេរៀនមួយនៅក្នុងការជួបជុំនីមួយៗ។ មេរៀននានាទាំងអស់មានរយៈពេលប្រហែលជា ៧៥នាទី។

### ប័ណ្ណព័ត៌មានលេខ

ប័ណ្ណព័ត៌មានលេខ គឺជាពាក្យខ្លីសម្រាប់ក្រដាសព័ត៌មាន។ ប័ណ្ណព័ត៌មានទាំងនេះគឺជាផ្នែកមួយនៃឧបករណ៍នាវិកវៃឆ្លាត។ ជាធម្មតា ក្រដាសទាំងនេះមានព័ត៌មានអំពីមេរៀន ឬក៏សកម្មភាពដែលអ្នកចូលរួមនឹងត្រូវបំពេញ ដូចជា ការណែនាំសម្រាប់ដើរតួនាទីមួយ។

## កូនសៀវភៅនារីកវៃឆ្លាត

អ្នកចូលរួមនីមួយៗនៅក្នុងក្លឹប SNYC ត្រូវបានចែកឲ្យនូវកូនសៀវភៅនារីកវៃឆ្លាតដែលសង្ខេបព័ត៌មានសំខាន់ៗនៅក្នុងឧបករណ៍នារីកវៃឆ្លាត។

ដាក់សំណួរសាកល្បងសមត្ថភាពឲ្យអ្នកចូលរួម ដោយសួរថា៖

- តើក្លឹប SNYC គឺជាអ្វី?
- តើអ្នកសម្របសម្រួល គឺជាអ្វី?
- តើឧបករណ៍នារីកវៃឆ្លាត គឺជាអ្វី?
- តើប័ណ្ណព័ត៌មានលេខ គឺជាអ្វី?
- តើកូនសៀវភៅនារីកវៃឆ្លាត គឺជាអ្វី?
- តើមេរៀន គឺជាអ្វី?
- តើមេរៀនមួយមានរយៈពេលប៉ុន្មាន?

ចូរពន្យល់ថាក្លឹប SNYC គឺជាក្លឹបយុវជនមួយដែលនឹងកើតឡើងនៅក្នុងភូមិរបស់អ្នកចូលរួម។ ក្លឹបនេះ ប្រហែលជាជួបជុំគ្នារាល់ពីរសប្តាហ៍ម្តង ដោយមានរយៈពេល ៧៥ នាទី (មួយម៉ោង និង១៥នាទី) នៅក្នុងការបញ្ចប់មេរៀនមួយ។

## តើយុវជននឹងសិក្សាអំពីអ្វី នៅក្លឹប SNYC?

ចូរពន្យល់ថា អំឡុងពេលរៀនមេរៀននីមួយៗ អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹបSNYC នឹងអនុវត្តតាមសេចក្តីណែនាំនៅក្នុងឧបករណ៍នារីកវៃឆ្លាតដើម្បីបង្រៀនយុវជនអំពី៖

- ការជួញដូរមនុស្ស
- ជំនាញជីវិត (ឧទាហរណ៍ របៀបនិយាយ និងស្តាប់ស្តាប់ឲ្យបានល្អ) ដែលនឹងជួយយុវជនទប់ទល់នឹងការជួញដូរមនុស្ស
- របៀបរៀបចំផែនការក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព
- របៀបចែករំលែកព័ត៌មានអំពីភាពគ្រោះថ្នាក់នៃការជួញដូរមនុស្សជាមួយអ្នកដទៃ

អ្នកសម្របសម្រួលក្លឹប SNYC នឹងប្រើប្រាស់សកម្មភាពនានាក្នុងការបង្រៀន រួមមានការគូរគំនូរ តុក្កតា ល្បែងនានានិងការដើរតួនាទី។ ក្លឹប SNYC គួរមានភាពសប្បាយរីករាយ។

## តើការធ្វើចំណាកស្រុក គឺជាអ្វី?

ចូរពន្យល់ថា ការធ្វើចំណាកស្រុកគឺជាពាក្យមួយដែលរៀបរាប់អំពីការប្តូរទីតាំងពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ជាសាមញ្ញគឺដើម្បីស្វែងរកការងារធ្វើ។

## តើការជួញដូរ គឺជាអ្វី?

ចូរពន្យល់ថា ពេលយុវជនចូលសិក្សាក្នុងក្លឹប SNYC ពួកគាត់នឹងយល់ស៊ីជម្រៅអំពីការជួញដូរមនុស្ស។ ទោះបីជាយ៉ាងណាក៏ដោយ ការពន្យល់ធម្មតាមួយនៃការជួញដូរមានដូចខាងក្រោម៖

***ការជួញដូរមនុស្ស*** គឺជាការប្រើល្បិច ឬក៏ការបង្ខិតបង្ខំមនុស្សឲ្យធ្លាក់ក្នុងទម្រង់ ដែលត្រូវបានកេងប្រវ័ញ្ចការងារ ដែលជនរងគ្រោះពិបាកក្នុងការចាកចេញ។ ការជួញដូរជាញឹកញាប់រួមមាន ការយកជនរងគ្រោះពីកន្លែងដែលពួកគេរស់នៅទៅកន្លែងមួយផ្សេងទៀតដោយបង្ខំ ឬក៏បោកបញ្ឆោត ដើម្បីកេញយកផលប្រយោជន៍ពីពួកគាត់។ ទោះបីជាយ៉ាងណាក៏ដោយ វាអាចទៅរួចក្នុងការដែលត្រូវបានគេជួញដូរដោយពុំបានធ្វើការផ្លាស់ប្តូរទីកន្លែង។

***ការបង្ខិតបង្ខំ៖*** ចូរពន្យល់ថា ពេលដែលមនុស្សត្រូវបានគេជួញដូរ ពួកគាត់អាចត្រូវបានបង្ខំនៅក្នុងរូបភាពផ្សេងៗគ្នា។ មនុស្សមួយចំនួនត្រូវបានគេបោកបញ្ឆោតដោយការប្រាប់ថាពួកគាត់នឹងមានការងារល្អមួយពេលដែលពួកគាត់មកដល់ហើយបន្ទាប់មកពួកគាត់ត្រូវបាន បង្ខំឲ្យធ្វើការងារផ្សេងមួយទៀត។ អ្នកផ្សេងទៀតត្រូវបានឃុំខ្លួននៅក្នុងរោងចក្រ ឬក៏នៅលើ ទូកហើយមិនអាចចាកចេញបាន។ អ្នកខ្លះទៀតត្រូវបានប្រាប់ថា ពួកអ្នកជួញដូរនឹងធ្វើបាបពួកគាត់ឬគ្រួសារពួកគាត់ ប្រសិនបើពួកគាត់ចាកចេញនោះ។ ទាំងនេះគឺជា ឧទាហរណ៍ខុសៗគ្នានៃការបង្ខិតបង្ខំ៖

***ការកេងយកផលប្រយោជន៍៖*** ពេលដែលមនុស្សប្រើប្រាស់អ្នកដទៃ ជាធម្មតាគឺដើម្បីប្រាក់ចំណេញនោះ ពួកគាត់កំពុងកេងយកផលប្រយោជន៍ពីអ្នកទាំងនោះ។ ពេលដែលមនុស្សត្រូវបានគេជួញដូរ ពួកគាត់អាចត្រូវបានគេកេងយកផលប្រយោជន៍ដោយការបង្ខំឲ្យធ្វើការងារដែលពួកគាត់មិនចង់ធ្វើ បង្ខំឲ្យធ្វើការដោយពុំមានប្រាក់កម្រៃឬមានប្រាក់កម្រៃតិចតួច បង្ខំឲ្យធ្វើការងារពាក់ព័ន្ធនឹងផ្លូវភេទ ឬក៏ពួកគាត់អាចត្រូវបានគេវះកាត់យកសេរីរាង្គទៅលក់។

## តើបំណិនជីវិត គឺជាអ្វី?

ចូរពន្យល់ថា បំនិនជីវិតគឺជាជំនាញផ្ទាល់ខ្លួនដែលជួយយើងនៅក្នុងជីវិត។ នៅក្នុងសៀវភៅណែនាំ ជំនាញទំនាក់ទំនងត្រូវបានបង្រៀន ឧទាហរណ៍ របៀបគ្រប់គ្រងអារម្មណ៍ និងរបៀបសម្រេចចិត្តដែលត្រឹមត្រូវ។ ចូរពន្យល់ថា ជំនាញទាំងនេះត្រូវបានប្រើប្រាស់ដើម្បីជួយការពារមនុស្សពីការជួញដូរ។

## តើនរណានឹងមកក្លឹប SNYC?

ចូរពន្យល់ថា ក្លឹប SNYC គឺសម្រាប់យុវជនអាយុចាប់ពី១២ ទៅ ១៧ឆ្នាំ នៅក្នុងសហគមន៍។ ក្លឹបនេះគឺសម្រាប់យុវជនណាដែលអាចកំពុងគិតថា ចង់ធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ។ យុវជនមួយចំនួននៅក្នុង ក្លឹប SNYC អាចមិនដឹងពីរបៀបអាន។ ក្លឹប SNYC ស្វាគមន៍យុវជនដែលមានជំនឿលើសាសនាណាមួយ ឬក៏អត់ជឿលើសាសនា។

## ការប្តេជ្ញាចិត្តចូលរួមក្នុងក្លឹប SNYC

ទោះបីជាម្តងម្កាល អ្នកចូលរួមមានហេតុផលច្បាស់លាស់ក្នុងការមិនមកជួបប្រជុំក្លឹបក៏ដោយ ក៏ពួកគាត់ត្រូវបានគេរំពឹងទុក និងលើកទឹកចិត្តឲ្យចូលរួមគ្រប់មេរៀនទាំងអស់។

## ពិន្ទុតាមប្រព័ន្ធផ្កាយ

ចូរពន្យល់ថា ដើម្បីកសាងការប្តេជ្ញាចិត្តនិងជំរុញវត្តមាននោះក្លឹប SNYC មានប្រព័ន្ធផ្កាយមួយ។ មានមេរៀនចំនួន៣១នៅក្នុងឧបករណ៍នារីកវៃឆ្លាតនេះរួមទាំងមេរៀនដែលជំរុញឲ្យមានកម្មវិធីសកម្មភាពនៅក្នុងសហគមន៍។ អ្នកចូលរួមទទួលបានផ្កាយមួយនៅគ្រប់មេរៀនដែលពួកគាត់បានចូលរួម។ អ្នកចូលរួមដែលទទួលបាន២២ផ្កាយ មានសិទ្ធិទទួលរង្វាន់លើកទឹកចិត្តកម្រិត១។ អ្នកចូលរួមដែលទទួលបានផ្កាយ ២៦ មានសិទ្ធិទទួលរង្វាន់លើកទឹកចិត្តកម្រិត ២ ហើយអ្នកចូលរួមដែលចូលរួមគ្រប់៣១មេរៀននោះ មានសិទ្ធិទទួលរង្វាន់លើកទឹកចិត្តកម្រិត៣។ អ្នកសម្របសម្រួលជាយុវជន ក៏មានសិទ្ធិទទួលបានផ្កាយរាល់ពេលពួកគាត់មានវត្តមានផងដែរ។

ចូរពន្យល់ថា បុគ្គលិកអង្គការទស្សនៈពិភពលោក និងអ្នកសម្របសម្រួល ក្លឹប SNYC អាចសម្រេចរួមគ្នាថា តើអ្វីគួរតែជារង្វាន់លើកទឹកចិត្ត។ រង្វាន់លើកទឹកចិត្តអាចរួមមាន៖

- វត្ថុដែលផ្តល់ជាអំណោយដល់អង្គការទស្សនៈពិភពលោកដូចជាសំបុត្រទស្សនាការប្រគុំតន្ត្រី ឬក៏អាហារយ៉ឺត
- អាហារយ៉ឺត ឬក៏ម្ហូបក្លឹប SNYC
- ការបង់ប្រាក់ចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានប្រធានបទទាក់ទងនឹងការធ្វើចំណាកស្រុក ដោយសុវត្ថិភាព
- ចូលរួមក្នុងព្រឹត្តិការណ៍ ឬការប្រជុំក្រៅផ្លូវការអំពីការប្រឆាំងការជួញដូរមនុស្សរបស់អង្គការទស្សនៈពិភពលោកក្នុងតំបន់

រង្វាន់ទាំងនេះ នឹងមានភាពខុសៗគ្នា សម្រាប់ក្លឹប SNYC នីមួយៗ។

## សកម្មភាព ៖ ល្បែងបោះបាល់រំលឹកមេរៀន

ចូរពន្យល់ថា អ្នកចូលរួមទាំងអស់នឹងលេងល្បែងមួយដើម្បីជួយដល់ការចងចាំនូវអ្វីដែលពួកគាត់បានរៀន។ ចូរពន្យល់ថា នឹងត្រូវបានលេងល្បែងនេះនៅពេលខាងមុខពេលពួកគាត់នៅក្នុងក្លឹប SNYC។ ល្បែងនេះឈ្មោះថា «ល្បែងបោះបាល់រំលឹកមេរៀន»។ ប្រើប្រាស់ច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ ១០ខ ៖ សំណួរល្បែងបោះបាល់រំលឹកមេរៀន១» ដើម្បីដឹកនាំក្រុមលេងល្បែងនេះ ដោយអនុវត្តតាមសេចក្តីណែនាំ។ អ្នកចូលរួមអាចមើលទៅសេចក្តីណែនាំនៅក្នុង «ប័ណ្ណព័ត៌មានលេខ១០ក ៖ ល្បែងពង្រឹងថ្នាក់»។

### តើអ្នកសម្របសម្រួល ក្លឹប SNYC គឺជាអ្វី?

អ្នកសម្របសម្រួល ក្លឹប SNYC មានពីរប្រភេទ គឺអ្នកសម្របសម្រួលជាមនុស្សពេញវ័យ និងអ្នកសម្របសម្រួលជាយុវជន។

អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC គឺជាអ្នករៀបចំសកម្មភាពក្នុងក្លឹប SNYC និងបង្រៀនមេរៀនដោយយោងតាមសេចក្តីណែនាំនៅក្នុងឧបករណ៍នារីកឆ្លាត។

អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC គឺជាអ្នកជួយដល់អ្នកសម្របសម្រួលជាមនុស្សពេញវ័យ។ ចូរពន្យល់ថា អ្នកនឹងពិភាក្សាអំពីការងាររបស់អ្នកសម្របសម្រួលជាយុវជន ប៉ុន្តែ នឹងពិភាក្សាអំពីផលប្រយោជន៍នៃការធ្វើជាអ្នកសម្របសម្រួលជាយុវជនម្នាក់ជាមុនសិន។

## ផលប្រយោជន៍នៃការធ្វើជាអ្នកសម្របសម្រួលជាយុវជនក្នុង ក្លឹប SNYC

ចូរពន្យល់ថា មានផលប្រយោជន៍ជាច្រើននៃការធ្វើជាអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ។ សូមអានចំណុចស្ដីពីផលប្រយោជន៍ខាងក្រោមឲ្យឮៗ ឲ្យក្រុមបានស្ដាប់ ៖

១. អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC នឹងរៀនអំពីជំនាញផ្សេងៗ។ ពួកគាត់ទទួលបានការបណ្ដុះបណ្ដាលអំពីរបៀបដឹកនាំក្រុម។ នេះរួមបញ្ចូលទាំងការបណ្ដុះបណ្ដាលនៅថ្ងៃនេះ និងការបណ្ដុះបណ្ដាលដែលយុវជនទទួលបានដោយការធ្វើជាអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC។

២. អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC នឹងទទួលបានបទពិសោធន៍ដែលនៅពេលក្រោយអាចជួយដល់ពួកគាត់ឲ្យចូលទៅក្នុងសាលាមួយដ៏ល្អ ឬទទួលបានការងារមួយដ៏ល្អ។ អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC អាចប្រាប់ដល់និយោជកថាពួកគាត់បានធ្លាប់ធ្វើការងារជាអ្នកមេដឹកនាំក្រុមយុវជន ហើយពួកគេមានចំណេះដឹងច្រើនទាក់ទងនឹងការប្រឆាំងការជួញដូរមនុស្សក៏ដូចជាជំនាញនិងបទពិសោធន៍ដឹកនាំ។

៣. អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC អាចស្នើសុំអ្នកសម្របសម្រួលពេញវ័យធ្វើជាអ្នកធានាអះអាងសម្រាប់ពួកគាត់ពេលដែលពួកគាត់ដាក់ពាក្យបម្រើការងារ ឬសុំចូលរៀននៅសាលាណាមួយ។

៤. អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC នីមួយៗទទួលបានលិខិតបញ្ជាក់នៅពេលបញ្ចប់វគ្គនៅក្លឹប SNYC។

៥. ប្រសិនបើអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC សិក្សាចប់ឧបករណ៍នារីកឆ្លាតនេះ ពួកគាត់មានសិទ្ធិក្នុងការចូលរួមវគ្គបណ្ដុះបណ្ដាលសៀវភៅមគ្គុទេសសម្រាប់អ្នកសម្របសម្រួលក្លឹបយុវជននារីកឆ្លាត ពេញលេញនៅវគ្គក្រោយ ហើយពួកគាត់ក៏មានសិទ្ធិដាក់ពាក្យសុំធ្វើជាអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC នៅវគ្គក្រោយផងដែរ។

៦. អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC អាចទទួលបានផ្កាយ និងមានសិទ្ធិទទួលរង្វាន់លើកទឹកចិត្ត។

៧. វាសប្បាយរីករាយ!

## តើនរណាជាអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC?

ចូរពន្យល់ថា មានអ្នកសម្របសម្រួល ក្លឹប SNYC ជាយុវជន រហូតដល់បួននាក់សម្រាប់ក្រុមនីមួយៗ។

ចូរពន្យល់ថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYCទាំងនេះត្រូវមាន៖

- អាយុពី ១៥-១៧ ឆ្នាំ
- ចេះអាន
- យុវជនដែលមានការទទួលខុសត្រូវ ដែលចូលរួមប្រជុំរបស់ ក្លឹប SNYC ទាំងអស់
- យុវជនដែលមានសណ្ដានចិត្តល្អ ដែលមិនត្រូវធ្វើបាប គំរាមកំហែង ឬធ្វើឲ្យយុវជនផ្សេងទៀតខ្មាស់គេ
- មកពីសហគមន៍តែមួយដូចយុវជនផ្សេងទៀតនៅក្នុង ក្លឹប SNYC ដែរ

### តើអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC មានភារកិច្ចអ្វីខ្លះ?

ប្រាប់អ្នកចូលរួមថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ត្រូវ៖

១. សម្របសម្រួលល្បែងពង្រឹងថ្នាក់នៅពេលចាប់ផ្ដើមមេរៀន

២. ជួយយុវជនដែលពិបាកក្នុងការអាន ឬសរសេរ ដោយជួយកត់ត្រាមតិយោបល់របស់ពួកគាត់

៣. ជួយសម្របសម្រួលការពិភាក្សានៅពេលដែលមានការបែងចែកជាក្រុមតូចៗ

៤. ជួយបង្កើតទំនាក់ទំនងរវាងយុវជន និងអ្នកសម្របសម្រួលពេញវ័យ

៥. ជួយអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC រៀបចំមេរៀន

ចូរពន្យល់ថានៅមេរៀនក្រោយសកម្មភាពទាំងនេះនឹងត្រូវបានពិភាក្សាមួយសកម្មភាពម្ដងៗដោយមានការពន្យល់អំពីថាតើសកម្មភាពនីមួយមានអ្វីខ្លះ។

#### សង្ខេបមេរៀន

- ក្លឹប SNYC គឺជាក្លឹបយុវជននារីកវៃឆ្លាត
- ប័ណ្ណព័ត៌មានលេខ គឺជាក្រដាសព័ត៌មាន
- ការជួញដូរមនុស្សគឺជាការបោកបញ្ឆោត ឬក៏ការបង្ខិតបង្ខំមនុស្សឲ្យធ្លាក់ក្នុងទម្រង់ដែលត្រូវបានកេងប្រវ័ញ្ចនៃការងារដែលជនរងគ្រោះពិបាកក្នុងការចាកចេញ
- បំនិនជីវិតគឺជាជំនាញផ្ទាល់ខ្លួនដែលជួយយើងនៅក្នុងជីវិតរស់នៅ
- ពិន្ទុតាមប្រព័ន្ធផ្កាយគឺជាប្រព័ន្ធមួយដែលអ្នកចូលរួមទទួលបានផ្កាយសម្រាប់មេរៀននីមួយៗដែលពួកគាត់បានរៀន។ ផ្កាយ = រង្វាន់។
- ក្លឹប SNYC មានអ្នកសម្របសម្រួលពេញវ័យ និងអ្នកសម្របសម្រួលជាយុវជន
- មានផលប្រយោជន៍ជាច្រើនដែលធ្វើជាអ្នកសម្របសម្រួលជាយុវជនម្នាក់

## ប័ណ្ណព័ត៌មានលេខ ១០.ក ៖ ល្បែងថាមពល

អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ដឹកនាំល្បែងថាមពល ។ អ្នកសម្របសម្រួលគួរចងចាំ៖

- និយាយដោយភាពរស់រវើក
- ស្តាប់យុវជនផ្សេងទៀត
- ធ្វើដៃជាកាយវិការនៅពេលនិយាយ
- ដើរជុំវិញបន្ទប់នៅពេលនិយាយ
- សម្លឹងមើលភ្នែកយុវជនផ្សេងទៀត
- កំប្លែងលេងសើច (ប៉ុន្តែមិនត្រូវសើចចំអកដល់អ្នកចូលរួម)
- ត្រូវប្រាកដថា អ្នកចូលរួមទាំងអស់មានឱកាសធ្វើសកម្មភាព
- ផ្ទៀងពេលវេលា និងបញ្ចប់ល្បែងនេះបន្ទាប់ពីរយៈពេល ១០ នាទី
- កុំប្រើពេលវេលាយូរពេកក្នុងការពន្យល់អំពីរបៀបលេងល្បែងពង្រឹងថ្នាក់
- កុំបង្ខំអ្នកចូលរួមណាមួយដើរតួ ប្រសិនបើគាត់មិនចង់
- មិនត្រូវធ្វើបាប ឬប្រមាថយុវជនផ្សេងទេ

## ១. ឈរជាជួរ

| | |
|---|---|
| **គោលបំណង ៖** ជួយអ្នកចូលរួមបង្កើតទំនាក់ទំនង មានសេចក្តីរីករាយ និងត្រៀមខ្លួនចាប់ផ្តើម | |
| **សម្ភារ ៖** គ្មាន | |
| **រយៈពេល ៖** ៥-១០ នាទី | |

### សកម្មភាព

១. បែងចែកអ្នកចូលរួមចេញជាក្រុមតូចៗដែលមានសមាជិក ៥-៦ នាក់

២. ប្រាប់ក្រុមនីមួយៗឲ្យរៀបចំសមាជិករបស់ខ្លួនដោយយោងទៅតាមប្រភេទដូចខាងក្រោម

ក. កម្ពស់ (ពីទាបទៅខ្ពស់)

ខ. អាយុ (ពីចាស់មកក្មេង)

គ. ទំហំប្រអប់ជើង

ឃ. ចម្ងាយផ្លូវធ្វើដំណើរមកក្លឹប

ង. ចំនួនបងប្អូនបង្កើត

៣. នៅពេលឮសញ្ញា សមាជិកក្រុមទាំងអស់គួររៀបចំយោងតាមប្រភេទ ហើយអង្គុយចុះ

៤. ដើម្បីឲ្យមានលក្ខណៈកាន់ប្រកួតប្រជែងប្រាប់ឲ្យអ្នកចូលរួមអនុវត្តសកម្មភាពដោយមិននិយាយគ្នាទៅវិញទៅមក

៥. ត្រួតពិនិត្យការរៀបចំនេះ

៦. ក្រុមដែលរៀបចំខ្លួនបានត្រឹមត្រូវមុនគេនឹងទទួលបានពិន្ទុមួយ

៧. នៅពេលក្រុមបានយល់ដឹងអំពីល្បែងនេះហើយ អ្នកចូលរួមអាចណែនាំប្រភេទផ្សេងទៀត

## ២. ល្បែងបោះបាល់ចាំឈ្មោះ

| | |
|---|---|
| **គោលបំណង** | ៖ ជួយឲ្យអ្នកចូលរួមស្គាល់គ្នា បង្កើតទំនាក់ទំនង បង្កើតភាពសប្បាយរីករាយ និងត្រៀមខ្លួន |
| **សម្ភារ ៖** បាល់ | |
| **រយៈពេល ៖** ៥-១០ នាទី | |

### សកម្មភាព

ឈរជារង្វង់មូល

២. កាន់បាល់នៅក្នុងដៃ

៣. និយាយឈ្មោះរបស់អ្នកនៅពេលកាន់បាល់បន្ទាប់មកនិយាយឈ្មោះម្តងទៀតពេលដែលអ្នកបោះបាល់ទៅអ្នកចូលរួមផ្សេងទៀត

៤. បន្តធ្វើដូច្នេះរហូតដល់អ្នកគ្រប់គ្នានៅក្នុងក្រុមបាននិយាយឈ្មោះម្នាក់ម្តង

៥. បន្ទាប់មកធ្វើសកម្មភាពនេះឡើងវិញ ក៏ប៉ុន្តែត្រូវឲ្យសមាជិកម្នាក់ដែលកំពុងកាន់បាលនិយាយឈ្មោះរបស់គេ បន្ទាប់មក ពេលបោះបាល់ និយាយឈ្មោះអ្នកចូលរួមដែលយើងបោះបាល់សំដៅទៅ។ ធ្វើដូច្នេះរហូតដល់អ្នកគ្រប់គ្នានៅក្នុងក្រុមមានឱកាសម្តងម្នាក់។

៦. ប្រសិនបើមានពេល អ្នកចូលរួមអាចនិយាយឈ្មោះផ្ទាល់របស់ខ្លួននិងអ្វីដែលពួកគាត់ចូលចិត្ត។ ល្បែងនេះអាចត្រូវលេងដោយយោងទៅតាមប្រភេទ (និយាយពីផ្លែឈើ ល្បែងបាល់ បទចម្រៀង និងអ្វីផ្សេងៗ)។

## ៣. អ្វីដែលអ្នកអាចមិនដឹង

| | |
|---|---|
| **គោលបំណង** | ៖ ជួយឲ្យអ្នកចូលរួមស្គាល់គ្នា បង្កើតទំនាក់ទំនង បង្កើតភាពសប្បាយរីករាយ និងត្រៀមខ្លួនចាប់ផ្តើម |
| **សម្ភារ** | ៖ មិនមាន |
| **រយៈពេល** | ៖៥-១០ នាទី |

### សកម្មភាព

១. ឲ្យអ្នកចូលរួមឈរជាជួរ

២. ឲ្យអ្នកចូលរួមដើរទៅជ្រុងម្ខាងនៃបន្ទប់ ហើយបន្ទាប់មកនិយាយអ្វីមួយអំពីខ្លួនឯងដែលអ្នកផ្សេងទៀតអាចមិនដឹង

ឧទាហរណ៍៖

- ខ្ញុំបានទៅលេងទីក្រុងម្តង
- ខ្ញុំចូលចិត្តការ៉េម
- ខ្ញុំអាចញាក់ស្លឹកត្រចៀករបស់ខ្ញុំ
- ខ្ញុំជាអ្នកចាំទីពេលលេងបាល់ទាត់

៣. អ្នកដែលមានលក្ខណៈពិសេស ឬបទពិសោធន៍ដូចគ្នានេះ គួររត់ទៅចូលរួមជាមួយអ្នកទី១

៤. ក្រោយមកពួកគាត់ទាំងអស់ត្រឡប់មករកជួរដើមវិញ

៥. ធ្វើសកម្មភាពនេះឲ្យបានច្រើនដងតាមដែលអាចធ្វើទៅបាន ប្រសិនបើមានពេលវេលា

## ៤. ល្បែងបោះបាល់រំឭកមេរៀន

| | |
|---|---|
| **គោលបំណង** | ៖ ជួយឲ្យអ្នកចូលរួមស្គាល់គ្នា បង្កើតទំនាក់ទំនង បង្កើតភាពសប្បាយរីករាយ និងត្រៀមខ្លួនចាប់ផ្តើម។ ល្បែងនេះក៏ប្រើប្រាស់ដើម្បីជួយរំលឹកឡើងវិញនូវប្រធានបទដែលបានពិភាក្សាកន្លងមក។ |
| **សម្ភារ** | ៖ បាល់ |
| **រយៈពេល** | ៖ ៥-១០ នាទី |

### សកម្មភាព

១. បែកចែកក្រុមទៅជាក្រុមតូចៗដែលមានសមាជិក៤នាក់

២. ក្រុមទាំងមូលឈរជារង្វង់ ដោយសមាជិកក្រុមតូចៗឈរជិតគ្នាទៅវិញទៅមក

៣. បោះបាល់ទៅក្រុមមួយ។ សួរក្រុមនោះនូវសំណួរមួយដែលទាក់ទងនឹងមេរៀនដែលបានរៀន។ មនុស្សបួននាក់នៅក្នុងក្រុម ពិភាក្សាគ្នាដើម្បីសម្រេចនូវចម្លើយត្រឹមត្រូវ។

៤. ប្រសិនបើក្រុមនោះឆ្លើយសំណួរបានត្រឹមត្រូវ ក្រុមនឹងទទួលបានពិន្ទុ១។ ប្រសិនបើឆ្លើយខុស បោះបាល់ទៅក្រុមមួយផ្សេងទៀត

៥. ធ្វើរបៀបនេះរហូតសំណួរទាំងអស់ត្រូវបានសួរ

## ៥. ល្បែងសំណួរសាកល្បងសមត្ថភាព

| | |
|---|---|
| **គោលបំណង** | ៖ ជួយឲ្យអ្នកចូលរួមរំលឹកមាតិកាដែលបានរៀននៅក្នុងមេរៀនរបស់ក្លឹបកន្លងមក |
| **សម្ភារ** | ៖ សំណួរសាកល្បងសមត្ថភាព រង្វាន់តិចតួច |
| **រយៈពេល** | ៖ ៥-១០ នាទី |

ល្បែងនេះមិនចាំបាច់ត្រូវយកគ្រប់សំណួរនៅក្នុងសំណួរសាកល្បងសមត្ថភាពមកសួរនោះទេ។ អ្នកអាចសួរសំណួរជាច្រើនទៅតាមពេលវេលាដែលអ្នកមានដើម្បីធ្វើការបូកសរុប។

មានសំណួរជាច្រើនរៀបរាប់នៅទីនេះ ដូច្នេះអ្នកអាចលេងល្បែងនេះបានច្រើនដងដោយសួរសំណួរខុសៗគ្នា។

សំណួរត្រូវបានចុះលេខរៀង ហើយចម្លើយមានជាចំណុចៗ និង*ត្រូវបានសរសេរជាអក្សរទ្រេត។*

មានសំណួរ និងចម្លើយជាច្រើនដែលហាក់ដូចជាមិនច្បាស់លាស់ រហូតដល់អ្នកបានអានមេរៀនដែលពាក់ព័ន្ធ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលអ្នកអានសៀវភៅណែនាំទាំងស្រុងបញ្ហាទាំងនេះគួរតែច្បាស់លាស់។ដូច្នេះសួរសំណួរដែលពាក់ព័ន្ធនឹងមេរៀនមួយតែប៉ុណ្ណោះ បន្ទាប់ពីអ្នកបានសម្របសម្រួលមេរៀននោះ (លេខរៀង មេរៀនត្រូវបានផ្តល់បន្ទាប់សំណួរនីមួយៗ)។

ប្រសិនបើក្រុមមួយឆ្លើយចម្លើយមិនត្រឹមត្រូវ យើងត្រូវបង្ហាញការគាំទ្រ។ មិនត្រូវបំបាក់មុខអ្នកចូលរួមទេ។ នេះមិនមែនជាការសាកល្បងសមត្ថភាពរបស់សាលាទេ។ ការសាកល្បងនេះមានបំណងបង្កើតការសប្បាយ។ ផ្តល់រង្វាន់តិចតួចសម្រាប់ការឆ្លើយសំណួរត្រូវ។

## ៦. ល្បែងលាក់ក្រណាត់ ឬលាក់កន្សែង

| | |
|---|---|
| **គោលបំណង** | ៖ ជួយឲ្យអ្នកចូលរួមមានភាពរីករាយ និងត្រៀមចាប់ផ្តើម |
| **សម្ភារ** | ៖ កន្សែង ឬក្រណាត់មួយផ្ទាំង |
| **រយៈពេល** | ៖ ៥-១០ នាទី |

### សកម្មភាព

១. ចូរពន្យល់ថា ល្បែងនេះគឺជាល្បែងថ្មីដែលមានលំនាំតាមល្បែងប្រពៃណីមួយដើម្បីឲ្យស្គាល់គ្នាកាន់តែច្បាស់

២. ក្រុមត្រូវអង្គុយជារង្វង់មូល

៣. អ្នកចូលរួមម្នាក់ដើរជុំវិញវង់ ហើយដាក់ក្រណាត់ឬក៏កន្សែងលើអ្នកចូលរួមម្នាក់ទៀតដែលអង្គុយ។ (ល្បែងនេះក៏អាចត្រូវបានលេងដោយការប៉ះស្មាជំនួសការប្រើប្រាស់កន្សែងផងដែរ)

៤. អ្នកចូលរួមទីពីរបន្ទាប់មកត្រូវដេញអ្នកទីមួយជុំវិញវង់

៥. ប្រសិនបើអ្នកទីពីរចាប់អ្នកទីមួយបាន អ្នកទីមួយត្រូវដើរជុំវិញរង្វង់ដើម្បីទម្លាក់កន្សែងម្តងទៀត

៦. ប្រសិនបើអ្នកទីពីរមិនអាចចាប់អ្នកទីមួយបានទេ អ្នកទីពីរត្រូវដើរទម្លាក់កន្សែងម្តង

## ប័ណ្ណព័ត៌មានលេខ ១០ខ៖ សំណួរល្បែងបាល់រំលឹកមេរៀនវគ្គ១

- តើក្លឹប SNYC គឺជាអ្វី?
- តើអ្នកសម្របសម្រួល គឺជាអ្វី?
- តើឧបករណ៍នារីកវៃឆ្លាត គឺជាអ្វី?
- តើប័ណ្ណព័ត៌មាន គឺជាអ្វី?
- តើកូនសៀវភៅនារីកឆ្លាត គឺជាអ្វី?
- តើមេរៀន គឺជាអ្វី?
- តើមេរៀនមួយមានរយៈពេលប៉ុន្មាន?
- តើការជួញដូរមនុស្ស គឺជាអ្វី?
- តើការធ្វើចំណាកស្រុក គឺជាអ្វី?
- តើយុវជននឹងរៀនអំពីអ្វីនៅ ក្លឹប SNYC?
- តើបំនិនជីវិត គឺជាអ្វី?
- តើអ្នកទទួលបានអ្វីខ្លះ នៅក្នុងការចូលរួមសិក្សាមេរៀន?
- តើមានមេរៀនចំនួនប៉ុន្មានដែលអ្នកត្រូវចូលរៀនដើម្បីទទួលបានរង្វាន់កម្រិត៣?

# មេរៀនទី១១៖ របៀបដឹកនាំល្បែងថាមពល

## វត្ថុបំណង

អ្នកចូលរួមនឹងយល់អំពីជំនាញសម្រាប់ដឹកនាំល្បែងថាមពល ។

## រយៈពេល

៦០ នាទី

## សម្ភារ

- ច្បាប់ចម្លងនៃ« ប័ណ្ណព័ត៌មានលេខ១០.ក ៖ ល្បែងថាមពល »សម្រាប់អ្នកចូលរួមនីមួយៗ
- ក្រដាសមួយសន្លឹកសម្រាប់អ្នកចូលរួមនីមួយៗ
- ប៊ិចពណ៌

## អ្នកចូលរួម

អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោក ឬអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ដែលបានបញ្ចប់ការបណ្តុះបណ្តាល អំពីឧបករណ៍នាវិកវៃឆ្លាត និងការបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួល។

## សេចក្តីណែនាំ

ចូរពន្យល់ថា រាល់មេរៀនទាំងអស់ចាប់ផ្តើមជាមួយនឹងល្បែងថាមពល ។«ល្បែងបោះបាល់ចងចាំឈ្មោះ» និង«ល្បែងបោះបាល់រំលឹកមេរៀន» ដែលបានលេងនៅក្នុងម៉ោងរៀនចុងក្រោយ គឺជាល្បែងកំដៅសាច់ដុំ។ ចូរពន្យល់ថាថ្ងៃនេះអ្នកចូលរួមទាំងអស់នឹងរៀនអំពីរបៀបដឹកនាំល្បែងទាំងនេះ។

## ហេតុអ្វីបានជាយើងលេងល្បែងថាមពល ?

សួរអ្នកចូលរួមថា តើហេតុអ្វីបានជាល្បែងពង្រឹងថ្នាក់នេះត្រូវបានលេង។

ចូរពន្យល់ថា ល្បែងទាំងនេះគឺសប្បាយ ក៏ប៉ុន្តែល្បែងទាំងនេះក៏បម្រើដល់គោលបំណងមួយផ្សេងទៀតផងដែរ។ ល្បែងទាំងនេះជួយឲ្យយុវជនមានអារម្មណ៍ធូរស្រាល និងមានអារម្មណ៍ថារីករាយមុនពេលចាប់ផ្តើមពិភាក្សា អំពីប្រធានបទដែលអាចពិបាកក្នុងការពិភាក្សា។ ល្បែងទាំងនេះជួយឲ្យក្រុមពិភាក្សាស្គាល់គ្នា និងជឿទុកចិត្តគ្នាទៅវិញទៅមក។ ហើយល្បែងទាំងនេះជួយផ្តល់ថាមពលដល់យុវជននៅពេលចាប់ផ្តើមមេរៀន។

ចូរពន្យល់ថា មានល្បែងពង្រឹងថ្នាក់ចំនួនប្រាំមួយក្នុងឧបករណ៍នារីកឆ្លាត និងនៅក្នុង «ប័ណ្ណព័ត៌មានលេខ១០ក ៖ ល្បែងល្បែងពង្រឹងថ្នាក់»។ ចូរពន្យល់ថា ពេលដែលអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ដឹកនាំល្បែងត្រៀមសម្រាប់ចាប់ផ្តើមទាំងនេះ ពួកគាត់នឹងអនុវត្តតាមសេចក្តីណែនាំ។

ចូរឲ្យអ្នកចូលរួមនីមួយៗនូវច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ១០ក ៖ ល្បែងពង្រឹងថ្នាក់» ហើយឲ្យអ្នកចូលរួមមើលល្បែងពង្រឹងថ្នាក់១ «ឈរជាជួរ»។

អនុវត្តតាមសេចក្តីណែនាំ ដើម្បីឲ្យអ្នកចូលរួមនឹងលេងល្បែងដោយយោងទៅតាមប្រភេទខុសគ្នាពីរ។ បន្ទាប់មកស្នើសុំអ្នកស្ម័គ្រចិត្តម្នាក់ឲ្យដើរតួជាអ្នកសម្របសម្រួល និងដឹកនាំល្បែងនេះ។

ធ្វើម្តងហើយម្តងទៀតរហូតទាល់តែអ្នកចូលរួមច្រើននាក់ មានឱកាសដើរតួជាអ្នកសម្របសម្រួលនៅក្នុងល្បែងនេះ។

ចូរពន្យល់ថានៅក្នុងការសិក្សារយៈពេលមួយថ្ងៃនេះនឹងមានការលេងល្បែងពង្រឹងថ្នាក់ទាំងប្រាំមួយ។ ល្បែងទាំងនេះត្រូវបានបង្រៀនពីព្រោះល្បែងត្រៀមសម្រាប់ចាប់ផ្តើមនេះអាចជួយឲ្យអ្នកចូលរួមនៅតែមានអារម្មណ៍ភ្លឺស្វាងពីមួយម៉ោងទៅមួយម៉ោង។

## ជំនាញធ្វើបទបង្ហាញ

សួរអ្នកចូលរួមថាតើពួកគាត់អាចចងចាំពេលវេលាដែលអង្គុយនៅក្នុងថ្នាក់ខណៈដែលគ្រូម្នាក់និយាយហើយ និយាយទៀតជាច្រើនម៉ោងដែរឬអត់? តើមាននរណាម្នាក់សម្លឹងទៅក្រៅបង្អួច និងរង់ចាំឲ្យពេលវេលាកន្លងផុតទៅឲ្យដល់ម៉ោងចេញដែរឬទេ?។ វាមានសារៈសំខាន់ដែលថា យុវជនគឺមិនមានការធុញទ្រាន់នៅក្នុងក្លឹប SNYC ឬក៏រង់ចាំតែម៉ោងចេញពីរៀននោះទេ។

ក្លឹប SNYC ត្រូវបានបង្កើតឡើងដើម្បីឲ្យយុវជនមានភាពសកម្ម។ គ្រប់មេរៀនទាំងអស់ចាប់ផ្តើមជាមួយនឹងល្បែងមួយ និងរួមបញ្ចូលសកម្មភាពមួយដែលធ្វើឲ្យយុវជនធ្វើអ្វីមួយដោយការលេង ឬក៏ធ្វើការងារជាក្រុម។ ប៉ុន្តែ ត្រូវពន្យល់ថា ទោះជាល្បែងពង្រឹងថ្នាក់ក៏អាចនឹងមានភាពធុញទ្រាន់ដែរ ប្រសិនបើអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC និយាយយូរពេក។ ចូរពន្យល់ថា ជំនាញសំខាន់មួយក្នុងការធ្វើបទបង្ហាញគឺត្រូវដឹងអំពីរបៀបនិយាយអំពីអ្វីដែលចាំបាច់នៅក្នុងរយៈពេលមួយដ៏ខ្លី។

សូមប្រាប់អ្នកចូលរួមថា វាពិតជាមានសារៈសំខាន់ណាស់ដែលថា ការលេងល្បែងពង្រឹងថ្នាក់គឺមិនមានរយៈពេលលើស១០នាទីទេ ហើយថាយុវជនអាចមានឱកាសចូលរួមលេង។ ទាំងនេះគឺជាការណែនាំដើម្បីដឹកនាំល្បែងពង្រឹងថ្នាក់៖

- កុំប្រើពេលយូរពេកក្នុងការពន្យល់អំពីរបៀបលេងល្បែងពង្រឹងថ្នាក់ ។
- កុំបង្ខំឲ្យយុវជនម្នាក់ចូលរួម ប្រសិនបើគេមិនចង់លេង។
- ត្រូវឲ្យអ្នកចូលរួមទាំងអស់មានឱកាសម្នាក់ម្តង
- ផ្ទៀងពេលវេលា និងបញ្ចប់ល្បែងនេះក្នុងរយៈពេល ១០នាទី

ចូរពន្យល់ថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ក៏អាចធ្វើឲ្យល្បែងត្រៀមសម្រាប់ចាប់ផ្តើមនេះមានភាពសប្បាយកាន់តែខ្លាំងដោយការនិយាយដោយមានថាមពល។ អ្នកសម្របសម្រួលក្លឹប SNYC គួរតែព្យាយាមដើម្បីធ្វើឲ្យមានការចាប់អារម្មណ៍។ ចូរពន្យល់ថា វិធីដែលអ្នកសម្របសម្រួលអាចធ្វើឲ្យមានការចាប់អារម្មណ៍រួមមាន៖

- ប្រើដៃធ្វើកាយវិការ នៅពេលនិយាយ
- ដើរជុំវិញបន្ទប់នៅពេលនិយាយ
- សម្លឹងមើលភ្នែកអ្នកចូលរួម
- កំប្លែងលេងសើច (ប៉ុន្តែ មិនត្រូវសើចចំអកដល់អ្នកចូលរួមទេ)
- ធ្វើឲ្យសប្បាយរីករាយ

## សកម្មភាព៖ ការអនុវត្តជំនាញធ្វើបទបង្ហាញ

ប្រាប់អ្នកចូលរួមឲ្យស្វែងរកដៃគូម្នាក់។ ប្រាប់ពួកគាត់ឲ្យទៅមើល «ប័ណ្ណព័ត៌មានលេខ ១០ល្បែងកំដៅសាច់ដុំ»។ ប្រាប់ពួកគេឲ្យអានសេចក្តីណែនាំដោយខ្លួនឯងដើម្បី «ឈរជាជួរ»។ បន្ទាប់មកឲ្យពួកគាត់ផ្លាស់ប្តូរវេនអានសេចក្តីណែនាំឲ្យដល់គ្នាទៅវិញទៅមក។

ចូរពន្យល់ថា នៅលើកដំបូងដែលពួកគាត់អានសេចក្តីណែនាំនេះឮៗ ពួកគាត់គួរធ្វើកាយវិការដៃបន្ថែមទៀតដើម្បីឲ្យន័យកាន់តែច្បាស់។

លើកទីពីរ ពួកគាត់ដើរជុំវិញបន្ទប់នៅពេលអានសេចក្តីណែនាំ

លើកទីបី ត្រូវសម្លឹងមើលភ្នែកដៃគូនៅពេលអានសេចក្តីណែនាំ

លើកចុងក្រោយ ត្រូវអានសេចក្តីណែនាំហាក់ដូចជារីករាយខ្លាំងអញ្ចឹង

បន្ទាប់មក ឲ្យដៃគូផ្លាស់ប្តូរតួនាទី ហើយអនុវត្តសកម្មភាពឡើងវិញ

### ការពិភាក្សា

ក្រោយពីគ្រប់គ្នាមានឱកាសធ្វើសកម្មភាពយ៉ាងយោចណាស់ពីរដងម្នាក់ ហើយប្រាប់ឲ្យអ្នកចូលរួមទាំងអស់រួមគ្នាជាក្រុមមួយហើយសួរថា ៖

- តើអ្នកមានអារម្មណ៍ដូចម្ដេចនៅពេលធ្វើសកម្មភាពនេះ?
- តើជំនាញមួយណា ដែលងាយស្រួលប្រើប្រាស់?
- តើជំនាញមួយណា ដែលពិបាកប្រើ?
- តើហេតុអ្វីបានជាជំនាញនោះពិបាក?
- តើអ្នកមានអារម្មណ៍ថា អ្នករីកចម្រើនដែរឬទេ នៅពេលដែលអ្នកកាន់តែអនុវត្ត?
- តើអ្នកមានល្បិចផ្ទាល់ខ្លួនណាមួយដែលធ្វើឲ្យងាយស្រួល ដែលអ្នកចង់ចែករំលែកដល់ក្រុមដែរឬទេ?

## សេចក្ដីណែនាំ៖ គ្មានអំពើហិង្សា ឬការប្រមាថ

ប្រាប់អ្នកចូលរួមឲ្យបិទភ្នែក ហើយគិតត្រឡប់ទៅពេលមួយនៅសាលា នៅពេលដែលគ្រូបានវាយ ឬប្រមាថខ្លួន។ ប្រាប់ឲ្យពួកគាត់ចងចាំនូវអ្វីដែលពួកគាត់បានគិត ហើយមានអារម្មណ៍ដូចម្ដេចនៅពេលនោះ។ សួរថា «តើអ្នកកំពុង គិតអំពីប្រធានបទដែលគ្រូកំពុងពិភាក្សា ឬតើអ្នកកំពុងមានអារម្មណ៍មិនសប្បាយចិត្ត និងខឹងយ៉ាងខ្លាំង ដែលបណ្ដាលមកពីវិធីដែលគ្រូបានវាយអ្នក?

ចូរពន្យល់ថា មនុស្សពេញវ័យមួយចំនួនជឿថា ការវាយ ការប្រមាថ ឬសើចចំអកដាក់យុវជននឹងបង្ខំឲ្យយុវជនរៀនសូត្រ។ នេះមិនពិតនោះទេ។ ការសិក្សាបង្ហាញថា ការរំលោភបំពានរាងកាយ ឬអារម្មណ៍បែបនេះ មានផលប៉ះពាល់ ផ្ទុយទៅវិញទេ។ វាធ្វើឲ្យយុវជនមានអារម្មណ៍ដែលរាំងស្ទះដល់ការសិក្សា។ ចូរពន្យល់ថា អ្នកសម្របសម្រួលក្លឹប SNYC ល្អមួយរូប៖

- មិនវាយ ឬធ្វើឲ្យរបួសរាងកាយយុវជន ទោះក្នុងលក្ខណៈណាក៏ដោយ
- មិនសើចចំអកយុវជន
- មិនប្រមាថយុវជន ទោះក្នុងលក្ខណៈណាក៏ដោយ (ឧទាហរណ៍ អ្នកសម្របសម្រួលមិនគួរប្រាប់ឲ្យយុវជន ឈរបែមុខទៅរកជញ្ជាំង ឬឲ្យអង្គុយនៅឆ្ងាយពីក្រុម ដើម្បីជាការដាក់ពិន័យនោះទេ។
- កុំធ្វើការប្រៀបធៀបអ្នកសម្របសម្រួលជាសាធារណៈ (ឧទាហរណ៍ អ្នកសម្របសម្រួលមិនគួរនិយាយថា អ្នកចូលរួមម្នាក់«ល្អណាស់» ហើយអ្នកចូលរួមម្នាក់ទៀត«អាក្រក់ណាស់» នោះទេ។ ប្រសិនបើអ្នកធ្វើអញ្ចឹង អ្នកចូលរួមអាក្រក់អាចឈប់មកកាន់ ក្លឹប SNYC)។

### ការគូររូប

ចែកក្រដាស និងប៊ិចទៅឲ្យយុវជន។ ប្រាប់ពួកគាត់ឲ្យគូររូបភាពអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ល្អម្នាក់ដែលដឹកនាំល្បែងពង្រឹងថ្នាក់។ ពេលដែលពួកគាត់គូររួច ដើរជុំវិញបន្ទប់ ហើយប្រាប់ឲ្យពួកគាត់បញ្ចូលសេចក្ដីលម្អិតនៅក្នុងគំនូររបស់ពួកគាត់ ដែលបង្ហាញអំពីអ្នកសម្របសម្រួល ក្លឹប SNYC ជាយុវជនកំពុងធ្វើកិច្ចការដូចខាងក្រោម៖

- ផ្ទៀងពេលវេលា
- និយាយដោយភាពរស់រវើក
- ដើរជុំវិញបន្ទប់
- ប្រើដៃជាកាយវិការ ដើម្បីសង្កត់ន័យឲ្យកាន់តែច្បាស់
- រួមបញ្ចូលយុវជនទាំងអស់នៅក្នុងក្រុម

### សង្ខេបមេរៀន

- ក្លឹប SNYC គឺជាក្លឹបយុវជននារីកវៃឆ្លាត
- ល្បែងពង្រឹងថ្នាក់ត្រូវបានដឹកនាំដោយអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC
- ល្បែងពង្រឹងថ្នាក់ទាំងប្រាំមួយត្រូវបានបង្រៀន
- អ្នកសម្របសម្រួលយុវជនដែលល្អរបស់ ក្លឹប SNYC ត្រូវៈ
  - ➢ និយាយដោយភាពរស់រវើក
  - ➢ ស្តាប់យុវជនផ្សេងទៀត
  - ➢ ប្រើកាយវិការដៃនៅពេលនិយាយ
  - ➢ ដើរជុំវិញបន្ទប់នៅពេលនិយាយ
  - ➢ សម្លឹងមើលភ្នែកយុវជនផ្សេងទៀត
  - ➢ កំប្លែងលេងសើច (ប៉ុន្តែ មិនត្រូវសើចចំអកដល់អ្នកចូលរួមទេ)
  - ➢ ត្រូវប្រាកដថា អ្នកចូលរួមទាំងអស់មានឱកាសធ្វើសកម្មភាពម្នាក់ម្តង
  - ➢ ផ្ទៀងពេលវេលា ហើយបញ្ចប់ល្បែងក្នុងរយៈពេល១០នាទី
  - ➢ កុំប្រើពេលយូរពេកក្នុងការពន្យល់អំពីរបៀបលេងល្បែងពង្រឹងថ្នាក់
  - ➢ កុំបង្ខំអ្នកចូលរួមណាឲ្យចូលរួម ប្រសិនបើអ្នកចូលរួមនោះមិនចង់ធ្វើសកម្មភាព
  - ➢ មិនត្រូវធ្វើបាប ឬប្រមាថយុវជនដទៃទៀតទេ

# មេរៀនទី១២ ៖ របៀបជួយយុវជនដែលមានបញ្ហាក្នុងការអាន

## វត្ថុបំណង

អ្នកចូលរួមនឹងយល់ដឹងអំពីរបៀបជួយយុវជនដែលមានបញ្ហាក្នុងការអាន។

## រយៈពេល

៦០ នាទី

## សម្ភារ

- ច្បាប់ចម្លង«ប័ណ្ណព័ត៌មានលេខ១០.ក. ល្បែងពង្រឹងថ្នាក់»សម្រាប់អ្នកចូលរួមនីមួយៗ
- ច្បាប់ចម្លង«ប័ណ្ណព័ត៌មានលេខ១២.ក. ការអាន» សម្រាប់យុវជនពាក់កណ្តាលនៅក្នុងក្រុម។ (ពួកគាត់នឹងអានជាគូ)

## អ្នកចូលរួម

អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោក ឬអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ដែលបានបញ្ចប់ការបណ្តុះបណ្តាល អំពីឧបករណ៍នាវិកវៃឆ្លាត និងការបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួល។

## សកម្មភាពត្រៀមសម្រាប់ចាប់ផ្តើម

ចូរពន្យល់ថា មេរៀននេះ នឹងចាប់ផ្តើមជាមួយនឹងល្បែងពង្រឹងថ្នាក់មួយផ្សេងទៀត។ ល្បែងនេះឈ្មោះថា «អ្វីដែលអ្នកអាចមិនដឹង»។ វាគឺជាល្បែងដ៏សប្បាយមួយដែលជួយឲ្យក្រុមរួបរួមគ្នា និងជួយឲ្យសមាជិកទទួលបានថាមពល។

សូមប្រាប់អ្នកចូលរួមឲ្យយក«ប័ណ្ណព័ត៌មានលេខ១០.ក. ល្បែងត្រៀមសម្រាប់ចាប់ផ្តើម» ចេញមក ហើយមើលទៅល្បែងដែលមានចំណងជើងថា «អ្វីដែលអ្នកអាចមិនដឹង»។

អនុវត្តតាមការណែនាំដើម្បីលេងល្បែង «អ្វីដែលអ្នកអាចមិនដឹង»ជុំទីមួយជាមួយនឹងអ្នកចូលរួម។ បន្ទាប់មកប្រាប់អ្នកចូលរួមឲ្យស្ម័គ្រចិត្តសម្របសម្រួលល្បែងនេះ។ ព្យាយាមជ្រើសរើសអ្នកស្ម័គ្រចិត្តដែលពុំបានដើរតួនាទីធ្វើជាអ្នកសម្របសម្រួលល្បែងត្រៀមសម្រាប់ចាប់ផ្តើមកាលពីមេរៀនមុន ។

## សេចក្តីណែនាំ ៖ ជួយយុវជនដែលមានការលំបាកក្នុងការអាន

ចូរពន្យល់ថា ការងារទីពីររបស់អ្នកសម្របសម្រួលជាយុវជនក្លឹប SYNC គឺជួយដល់អ្នកចូលរួម ដែលមានបញ្ហាក្នុងការអាន។ ប្រហែលជាមានយុវជននៅក្នុងក្លឹបដែលមិនបានយល់ដឹងពីរបៀបអាន ឬក៏អាចអានបានតិចតួច។

ចូរពន្យល់ថា យុវជនដែលមិនអាចអានបាន ក៏ឆ្លាតដូចយុវជនផ្សេងទៀតដែរ។ ពួកគាត់អាចមានគំនិតល្អៗ និងមតិយោបល់មានតម្លៃ។ រឿងដែលសំខាន់គឺពួកគេចូលរួមនៅក្នុងក្លឹប SNYC ដើម្បីសិក្សា និងចែករំលែកមតិយោបល់។

### តើយើងអាចដាក់បញ្ចូលយុវជនដែលមិនអាចអានបាននៅក្នុង ក្លឹប SNYC ដោយរបៀបណា?

ចូរពន្យល់ថា មានវិធីជាច្រើនដែលអ្នកសម្របសម្រួលក្លឹប SNYC ជាយុវជនអាចធ្វើបានដើម្បីជួយយុវជនដែលមិនអាចអានបាននៅក្នុងក្លឹប។

**១. អានឯកសារ និមិត្តសញ្ញា និងផ្លិបឆាតឲ្យឮៗ**

ចូរប្រាប់អ្នកចូលរួមថា ការងារមួយរបស់អ្នកសម្របសម្រួលជាយុវជនក្លឹប SYNC គឺត្រូវអានឲ្យបានឮៗឲ្យយុវជនផ្សេងទៀតស្តាប់។ ប្រសិនបើ មេរៀនមានក្រដាសព័ត៌មាន ប័ណ្ណព័ត៌មាន និមិត្តសញ្ញា ឬ ផ្លិបឆាត អ្នកសម្របសម្រួលជាយុវជនក្លឹប SYNC គួរអានអក្សរទាំងនេះឲ្យយុវជនដែលមិនចេះអានបានស្តាប់។ ជួនកាល មានការស្នើសុំឲ្យអ្នកសម្របសម្រួលយុវជនក្លឹប SYNC អានក្រដាសព័ត៌មានឲ្យឮៗទៅកាន់ក្រុមទាំងមូល។ ពេលខ្លះទៀត អ្នកសម្របសម្រួល SYNC ជាយុវជនអាចអង្គុយជាប់យុវជនដែលមិនចេះអាន ហើយអានឮតិចៗឲ្យពួកគាត់ស្តាប់។

**២. ចាប់ដៃគូជាមួយយុវជន ដែលពិបាកក្នុងការអាន**

ចូរពន្យល់ថាអំឡុងពេលធ្វើសកម្មភាពអ្នកសម្របសម្រួល SYNCជាយុវជនម្នាក់ជារឿយៗនឹងចាប់ដៃគូជាមួយយុវជនដែលមិនអាចអានបាន។ អ្នកសម្របសម្រួលយុវជនក្លឹប SYNC គួរអានឯកសារឲ្យដៃគូរបស់គេ ហើយបន្ទាប់មក សូមសួរថាតើដៃគូរបស់ខ្លួនគិតថាចម្លើយគឺជាអ្វី។ អ្នកសម្របសម្រួល SYNC ជាយុវជន បន្ទាប់មក អាចបញ្ចូលមតិយោបល់របស់ដៃគូជាមួយនឹងមតិយោបល់របស់ខ្លួន ហើយកត់ត្រាមតិយោបល់ទាំងនោះ។ វាពិតជាមានសារៈសំខាន់ណាស់ដែលអនុញ្ញាតឲ្យយុវជនដែលមិនអាចអានបានគិត និងឆ្លើយតាមគំនិតខ្លួនឯង គឺមិនគ្រាន់តែឆ្លើយជំនួសពួកគាត់នោះទេ។

### ៣. ចូលរួមក្នុងក្រុមការងារតូចៗ ជាមួយយុវជនដែលមានការលំបាកក្នុងការអាន

សូមប្រាប់អ្នកចូលរួមថា ប្រសិនបើ ក្លឹប SNYC បែងចែកជាក្រុមតូចៗនោះ យុវជនដែលមិនអាចអានបាន គួរចូលរួមនៅក្នុងក្រុម ដែលមានអ្នកសម្របសម្រួលយុវជនក្លឹប SYNC មួយរូប ឬ ច្រើន។ នេះមានន័យថា អ្នក សម្របសម្រួលយុវជន SYNC ម្នាក់អាចជួយសម្របសម្រួលការពិភាក្សាក្នុងក្រុម ហើយអាចជួយយុវជនដែល មិនអាចអានបានធ្វើការងារក្នុងក្រុម។

ឥរិយាបទចំពោះយុវជនដែលមានការលំបាកក្នុងការអាន

ចូរពន្យល់ថា អ្នកសម្របសម្រួលយុវជន SYNC គួរមានឥរិយាបទដោយការគោរពចំពោះយុវជនដែលមានការលំបាកក្នុងការអាន។ ចូរពន្យល់ថា អ្នកសម្របសម្រួលយុវជន SYNC គួរអនុវត្តតាមគោលការណ៍ណែនាំទាំងនេះ៖

- ព្យាយាមកំណត់អត្តសញ្ញាណយុវជនដែលត្រូវការជំនួយក្នុងការអាន ដោយកុំឲ្យពួកគាត់មានការចាប់អារម្មណ៍ចំពោះ។
- មិនត្រូវចំអន់ ឬក៏សើចចំអកឲ្យយុវជនដែលមានការលំបាកក្នុងការអានទេ។
- មិនត្រូវប្រាប់មនុស្សផ្សេងទៀតថា អ្នកណាគឺជាអ្នកដែលមិនអាចអានបាននោះទេ។
- មិនត្រូវធ្វើឲ្យមានការចាប់អារម្មណ៍ទៅលើអ្នកដែលមិនអាចអានបាននោះទេ ទោះក្នុងលក្ខណៈណាក៏ដោយ
- ត្រូវមានការអត់ធ្មត់។

### សកម្មភាព

សូមប្រាប់អ្នកចូលរួមឲ្យចាប់ដៃគូ ហើយចែកនូវឯកសារ «ប័ណ្ណព័ត៌មានលេខ១២.ក. ការអាន»។ ឲ្យអ្នកចូលរួមអានសេណារីយ៉ូ និងឆ្លើយសំណួរខាងក្រោម។

ពេលដែលពួកគាត់អានចប់រួចរាល់ សូមប្រាប់ដៃគូឲ្យចែករំលែកចម្លើយរបស់ពួកគាត់។ អនុញ្ញាតឲ្យអ្នកចូលរួមពិភាក្សាចម្លើយរបស់ពួកគាត់ ហើយបន្ទាប់មក បន្ថែមចម្លើយណាមួយដែលយកចេញពី «ប័ណ្ណព័ត៌មានលេខ១២.ខ. ចម្លើយលើការអាន» ដែលមិនទាន់ត្រូវបានលើកឡើង។

**សង្ខេបមេរៀន**

- អានឯកសារ និមិត្តសញ្ញា ឬផ្ទិបផាត ឮឲ្យអ្នកដែលមិនអាចអានបានស្តាប់
- ចាប់ដៃគូជាមួយអ្នកមិនអាចអានបាន
- ជួយយុវជនមិនអាចអានបាននៅពេលណាដែលក្រុមត្រូវបានបំបែកជាក្រុមតូចៗ
- ត្រូវមានការគោរពចំពោះយុវជនដែលពិបាកក្នុងការអាន
- មិនត្រូវប្រាប់យុវជនផ្សេងទៀតនៅក្នុងក្រុមទេ ប្រសិនបើអ្នកស្គាល់យុវជនម្នាក់ដែលមិនអាចអានបាន

## ប័ណ្ណព័ត៌មានលេខ ១២.ក.ការអាន

K គឺជាក្មេងប្រុសអាយុ ១៨ឆ្នាំ ជំវែវ្លាតម្នាក់ ដែលមកពីគ្រួសារក្រីក្រមួយ។ ក្មេងប្រុសនេះបានបោះបង់ការសិក្សានៅអាយុ ៩ឆ្នាំ ពីព្រោះគ្រួសាររបស់ក្មេងនេះមិនមានប្រាក់បង់ថ្លៃសាលាបានទេ។ K ដើរលក់សៀវភៅ និងប័ណ្ណប្រៃសនីយ៍តាមដងផ្លូវនៅពេលយប់ដើម្បីជួយគ្រួសារ។ Kកំពុងគិតអំពីការធ្វើចំណាកស្រុក ដើម្បីស្វែងរក ការងារមួយល្អជាងនេះនៅពេលដែល K បានជួបជាមួយបុគ្គលិកអង្គការទស្សនៈពិភពលោកម្នាក់ ដែលបានសុំឲ្យK ចូលរួមក្នុង SYNC។

K បានទៅចូលរួមក្នុងក្លឹបជាលើកដំបូង។ ពេលដែល K អង្គុយជាមួយអ្នកផ្សេងទៀតនោះ K មានភាពភ័យខ្លាច ពីព្រោះ K មិនអាចអានអក្សរបានច្រើននោះទេ។

អ្នកសម្របសម្រួលជាមនុស្សពេញវ័យ បាននិយាយអំពីប្រព័ន្ធផ្កាយ ហើយបានសរសេរអំពីវង្វាន់កម្រិត១ ២ និង៣ នៅលើផ្ទាំងផ្លិបឆាត ដើម្បីឲ្យអ្នករាល់គ្នាបានឃើញ។ K មិនអាចអាននូវអ្វីដែលអ្នកសម្របសម្រួលបានសរសេរនោះទេ។

ក្រោយមក អ្នកសម្របសម្រួលពេញវ័យបានឲ្យបំបែកជាក្រុមតូចៗ ដែលមាន សមាជិកពី ៤ ទៅ ៦នាក់ ដើម្បីពិភាក្សាអំពីវិន័យរបស់ក្លឹប។ K មានការភ័យខ្លាចថា យុវជន ផ្សេងទៀតនឹងឲ្យខ្លួនសរសេរចម្លើយ។

បន្ទាប់មក អ្នកសម្របសម្រួលពេញវ័យ បានប្រគល់ក្រដាសព័ត៌មាន (ប័ណ្ណព័ត៌មានលេខ)ដែល K មិនអាចអានបាន។ ប្រសិនបើអ្នកជាអ្នកសម្របសម្រួលជាយុវជននៅក្នុង ក្លឹប SNYC នេះ តើអ្នកនឹងជួយ K យ៉ាងដូចម្ដេច?

## ប័ណ្ណព័ត៌មានលេខ ១២.ខ. ចម្លើយលើការអាន

អ្នកសម្របសម្រួលគួររក្សាចម្លើយទាំងនេះ ហើយមិនត្រូវប្រគល់ឲ្យទេ។

អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC អាចធ្វើ៖

- មិនត្រូវធ្វើឲ្យមានការចាប់អារម្មណ៍ថា K មិនអាចអានបាននោះទេ
- អង្គុយជិត K
- អានព័ត៌មានលើផ្ទាំងហ្លិបឆាត ឮតិចៗ ឲ្យ K ស្ដាប់ ពេលដែលអ្នកសម្របសម្រួលពេញវ័យសរសេរ
- ចូលរួមក្រុមជាមួយ K នៅក្នុងការពិភាក្សាក្រុមតូចៗ ហើយស្ម័គ្រចិត្តធ្វើជាអ្នកកត់ត្រាមតិយោបល់របស់ អ្នកគ្រប់គ្នា
- អង្គុយជាប់ K ហើយអាន ប័ណ្ណព័ត៌មានលេខ ឲ្យឮៗ

# មេរៀនទី១៣៖ របៀបជួយសម្របសម្រួលកិច្ចពិភាក្សាតាមក្រុមតូចៗ

## វត្ថុបំណង

អ្នកចូលរួមនឹងយល់ដឹងអំពីរបៀបសម្របសម្រួលការពិភាក្សាតាមក្រុមតូចៗ

## រយៈពេល

៦០ នាទី

## សម្ភារ

- ច្បាប់ចម្លង«ប័ណ្ណព័ត៌មានលេខ១០.ក. ល្បែងពង្រឹងថ្នាក់»សម្រាប់អ្នកចូលរួមនីមួយៗ
- ឯកសារចម្លង «ប័ណ្ណព័ត៌មានលេខ ១០.ក. ល្បែងពង្រឹងថ្នាក់»សម្រាប់អ្នកចូលរួមនីមួយៗ
- ឯកសារចម្លងចំនួនប្រហែលប្រាំច្បាប់មាន
  - «ប័ណ្ណព័ត៌មានលេខ ១៣ .ក. ដើរតួនាទីពិភាក្សា» ដែលត្រូវបែងចែកតាមប័ណ្ណដោយឡែកៗ
  - «ប័ណ្ណព័ត៌មានលេខ ១៣ ខ.សម្របសម្រួលការពិភាក្សា» មួយច្បាប់សម្រាប់ក្រុមនីមួយៗ
- មតិយោបល់បានមកពី «ប័ណ្ណព័ត៌មានលេខ ១៣ .ក. ដើរតួនាទីពិភាក្សា» គួរត្រូវបានបំបែកជាមតិយោបល់ដោយឡែកៗមុនពេលចាប់ផ្តើមមេរៀន។

## អ្នកចូលរួម

អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោក ឬ អ្នកសម្របសម្រួលពេញវ័យក្នុងក្លឹប SNYC ដែលបានបញ្ចប់ការបណ្តុះបណ្តាលអំពីឧបករណ៍នាវិកវៃឆ្លាត និងការបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួល។

## សកម្មភាពត្រៀមសម្រាប់ចាប់ផ្តើម

ចូរពន្យល់ថា យើងនឹងចាប់ផ្តើមមេរៀននេះជាមួយនឹងល្បែងពង្រឹងថ្នាក់ ដែលមានឈ្មោះថា«ល្បែងបាល់ចងចាំឈ្មោះ»ហើយល្បែងនេះគឺជាល្បែងដែលក្រុមបានលេងនៅពេលចាប់ផ្តើមនៃសិក្ខាសាលាថ្ងៃនេះ។ប្រាប់អ្នកចូលរួមឲ្យយកច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ ១០.ក. ល្បែងត្រៀមសម្រាប់ចាប់ផ្តើម» ចេញមក។

មើលទៅចំណុចល្បែងដែលមានឈ្មោះថា«ល្បែងបាល់ចងចាំឈ្មោះ»។

សូមអនុវត្តតាមសេចក្តីណែនាំដើម្បីលេងល្បែង«ល្បែងបាល់ចងចាំឈ្មោះ» មួយជុំជាមួយអ្នកចូលរួម។ បន្ទាប់មកឲ្យអ្នកចូលរួមស្ម័គ្រចិត្តធ្វើជាអ្នកសម្របសម្រួលល្បែងនេះ។ រំលឹកពួកគាត់ឲ្យប្រើប្រាស់ជំនាញក្នុងការធ្វើបទបង្ហាញដែលពួកគេបានរៀននៅមុននេះ។ ព្យាយាមជ្រើសរើសអ្នកស្ម័គ្រចិត្ត ដែលពុំធ្លាប់ធ្វើជាអ្នកសម្របសម្រួលនៅក្នុងល្បែងកំដៅសាច់ដុំនៅក្នុងម៉ោងរៀនកន្លងមក។

## សេចក្តីណែនាំ៖ ជំនាញសម្របសម្រួល

ឥឡូវចូរពន្យល់ថា ជាញឹកញាប់ អ្នកសម្របសម្រួលពេញវ័យក្នុងក្លឹប SNYC នឹងប្រាប់អ្នកចូលរួមឲ្យបែកចែងជាក្រុមតូចៗដើម្បីពិភាក្សា ឬក៏ឆ្លើយសំណួរអំពីបញ្ហាជាក់ស្តែង។ ពេលបែងចែកជាក្រុមតូចៗ ដូច្នេះ អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC នឹងជួយសម្របសម្រួលការពិភាក្សានេះ។

សូមប្រាប់អ្នកចូលរួមថា ការសម្របសម្រួលក្នុងការពិភាក្សាគឺមានលក្ខណៈខុសគ្នាទៅនឹងការដឹកនាំល្បែងកំដៅសាច់ដុំ។ ពេលដែលអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ដឹកនាំសកម្មភាពលេងល្បែង ពួកគាត់នឹងធ្វើការណែនាំ និងប្រាប់អ្នកផ្សេងទៀតនូវអ្វីដែលត្រូវធ្វើ។ ប៉ុន្តែ នៅពេលពួកគាត់សម្របសម្រួលការពិភាក្សាមួយ ពួកគាត់ជួយដល់អ្នកចូលរួមផ្សេងទៀតឲ្យចែករំលែកគំនិតរបស់ពួកគាត់ ហើយត្រូវធ្វើឲ្យប្រាកដថា អ្នកចូលរួមទាំងអស់មានឱកាសនិយាយ។ ពេលដែលពួកគាត់សម្របសម្រួលកិច្ចពិភាក្សាពួកគាត់ត្រូវតែសួរសំណួរឲ្យបានច្រើន។

ចូរពន្យល់ថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC មានបច្ចេកទេស ដែលអាចយកមកប្រើប្រាស់ដើម្បីជំរុញឲ្យអ្នកផ្សេងទៀតនិយាយ។ សូមអានបច្ចេកទេសទាំងនេះឲ្យឮៗដល់ក្រុម ហើយសួរថាតើអ្នកចូលរួមមានសំណួរដែរ ឬអត់។

### របៀបសម្របសម្រួលការពិភាក្សា

- **បញ្ចូលអ្នកចូលរួមដែលស្ងាត់ស្ងៀមក្នុងក្រុម៖** សង្កេតមើលក្រុម។ ប្រសិនបើនរណាម្នាក់មិននិយាយទេ សូមសួរពួកគាត់ដោយទន់ភ្លន់ថា តើពួកគាត់មានទស្សនៈយ៉ាងណាដែរ ចំពោះប្រធានបទនេះ។ សូមកុំបង្ខំអ្នកចូលរួមឲ្យនិយាយប៉ុន្តែអញ្ជើញពួកគាត់ ប្រសិនបើពួក គាត់ស្ម័គ្រចិត្ត។

- **ដាក់កំណត់លើអ្នកដែលនិយាយច្រើន៖** ប្រសិនបើអ្នកចូលរួមម្នាក់និយាយតែឯងនោះ សូមស្នើសុំដោយគួរសមឲ្យគាត់ផ្ដល់ឱកាសដល់អ្នកដទៃផង។ ឧទាហរណ៍រង់ចាំដល់ពេលអ្នកចូលរួមនោះនិយាយចប់ប្រយោគរបស់គាត់ហើយនិយាយថា«អរគុណសម្រាប់ការបញ្ចេញមតិ។ **សូមទោសដែលបញ្ឈប់អ្នកត្រឹមនេះ ប៉ុន្តែយើងមានពេលវេលាកំណត់។ តើខ្ញុំអាចសួរថាតើមាននរណាផ្សេងទៀតមានយោបល់លើបញ្ហានេះទេ?»**
- **និយាយឡើងវិញ៖** អ្នកអាចជួយឲ្យការពិភាក្សាមានដំណើរការទៅបានដោយនិយាយឡើងវិញនូវអ្វី ដែលនរណាម្នាក់ទើបបាននិយាយ ហើយសួរថាតើអ្នកដទៃទៀតយល់ស្រប ឬមិនយល់ស្រប។ ឧទាហរណ៍ «នាង ទើបនិយាយថា______________ ។ **តើអ្នកយល់ស្របដែរឬទេ?**
- **ស្ដាប់៖** ប្រសិនបើអ្នកពិតជាស្ដាប់អ្វី ដែលយុវជននិយាយ ពួកគាត់នឹងកាន់តែចង់និយាយថែមទៀត។ អ្នកក៏អាចគិតនូវសំណួរពាក់ព័ន្ធនានា ដែលអាចជួយដល់ការពិភាក្សា។
- **សួរសំណួរច្រើន៖** សំណួរទាំងនេះ គួរជា**សំណួរអំពីអ្វីដែលយុវជនដទៃទៀតគិត ឬជឿ** មិនមែនគ្រាន់តែជា សំណួរដែលសាកល្បងចំណេះដឹងអំពីការពិតនោះទេ។ ឧទាហរណ៍នៃសំណួរអំពីអ្វីដែលយុវជនគិត ឬជឿ រួមមាន៖
  - «តើអ្នកគិតថាជាមូលហេតុអ្វីខ្លះដែលធ្វើឲ្យយុវជនចាកចេញពីសាលារៀន?
  - «តើអ្នកគិតថា អ្នកអាចប្រើប្រាស់បញ្ជីត្រួតពិនិត្យទាំងនេះក្នុងជិវិតផ្ទាល់ខ្លួនអ្នកដែរឬទេ? ហេតុអ្វីអាចប្រើប្រាស់បាន ឬ ហេតុអ្វីមិនអាច?

  សំណួរអំពីចំណេះដឹងគឺ៖
  - «ប្រាប់ឈ្មោះប្រទេសមួយដែលជាគោលដៅពេញនិយមសម្រាប់ការជួញដូរ»
- នៅក្នុងសៀវភៅឧបករណ៍នារីកវៃឆ្លាត (SNT) យើងប្រើប្រាស់សំណួរជាច្រើនដែលនិយាយអំពីគំនិត និងមតិយោបល់។

## សកម្មភាព៖ សម្របសម្រួលការពិភាក្សា

បែងចែកអ្នកចូលរួមជាក្រុម ដែលមួយក្រុមមានសមាជិក៨នាក់។ សូមប្រគល់ឲ្យអ្នកចូលរួមម្នាក់ៗនូវប័ណ្ណមួយ យកមកពី «ប័ណ្ណព័ត៌មានលេខ១៣.ក ដើរតួពិភាក្សា»។ បន្ទាប់មកឲ្យក្រុមនីមួយៗនូវឯកសារចម្លងនៃ «ប័ណ្ណព័ត៌មានលេខ ១៣.ខ សម្របសម្រួលការពិភាក្សា»។ ចូរពន្យល់ថា អ្នកនឹងដើរតួក្នុងការពិភាក្សា ហើយអ្នកចូលរួមម្នាក់ៗគួរសំដែង ដូចដែលបានណែនាំនៅលើប័ណ្ណ ដែលខ្លួនទទួលបាន។ ចូរពន្យល់ថា អ្នកខ្លះអាចត្រូវបានណែនាំឲ្យសំដែងរបៀបជាមនុស្សឈ្លើយបន្តិច ហើយអ្នករាល់គ្នាត្រូវចាំថាពួកគាត់គ្រាន់តែសំដែងតែប៉ុណ្ណោះ។ អ្នកដែលទទួលបានប័ណ្ណដើរតួជាអ្នកសម្របសម្រួលគួរព្យាយាមប្រើប្រាស់បច្ចេកទេសដែលមាននៅក្នុង «ប័ណ្ណព័ត៌មាន លេខ ១៣.ខ សម្របសម្រួលការពិភាក្សា»។

អ្នកសម្របសម្រួល គួរជ្រើសរើសប្រធានបទមួយក្នុងចំណោមប្រធានបទដូចខាងក្រោម នេះដើម្បីពិភាក្សា៖

- ភាពយន្តពេញនិយម
- បទភ្លេងពេញនិយម
- អាហារបរទេស
- អ្នកកីឡាល្បីល្បាញ

ចូរពន្យល់ថា គោលបំណង គឺត្រូវពិភាក្សាប្រធានបទដែលមិនទាក់ទងនឹងការជួញដូរ ដើម្បីឲ្យអ្នកចូលរួមអាចផ្តោតលើជំនាញសម្របសម្រួល។

ចូរពន្យល់ថា ក្រុមគួរពិភាក្សាប្រធានបទមួយរយៈពេលប្រហែល៥នាទី។ នៅពេលដែលពួកគាត់បញ្ចប់ សមាជិកនីមួយៗដាក់ប័ណ្ណទៅក្នុងប្រអប់មួយ ច្របល់បញ្ចូលគ្នា ហើយជ្រើសរើសប័ណ្ណថ្មី។ (ប្រសិនបើនរណាម្នាក់ទទួលបានប័ណ្ណជាអ្នកសម្របសម្រួលពីរដង គាត់គួរដាក់ប័ណ្ណនោះចូលទៅក្នុងប្រអប់វិញ ហើយយកប័ណ្ណផ្សេងមួយទៀត)។

ក្រុមគួរធ្វើបែបនេះសារឡើងវិញ៣ ឬ៤ដង ដើម្បីអាចឲ្យអ្នកចូលរួមមានឱកាសដើរតួផ្សេងៗ។

នៅពេលដែលពួកគាត់បញ្ចប់ ប្រាប់អ្នកចូលរួមឲ្យរួមជាមួយគ្នាជាក្រុមមួយ។ សួរថា៖

- តើមានអារម្មណ៍ដូចម្តេចក្នុងការអនុវត្តសកម្មភាពនេះ?
- តើជំនាញមួយណាដែលងាយស្រួលប្រើប្រាស់?
- តើជំនាញមួយណាដែលពិបាក?
- ហេតុអ្វីបានជាជំនាញនោះពិបាក?
- តើអ្នកមានអារម្មណ៍ថា អ្នករីកចម្រើនដែរ ឬទេ នៅពេលដែលអ្នកអនុវត្តកាន់តែច្រើន?
- តើនរណាមានវិធីសាស្រ្តផ្ទាល់ខ្លួនណាមួយ ដែលធ្វើឲ្យការពិភាក្សាមានភាពងាយស្រួលឡើង? តើអ្នកចង់ចែករំលែកដល់ក្រុមដែរ ឬទេ?

**សង្ខេបមេរៀន**

- ការសម្របសម្រួលកិច្ចពិភាក្សាគឺខុសគ្នាទៅនឹងការដឹកនាំល្បែងពង្រឹងថ្នាក់។ នៅក្នុងការពិភាក្សា អ្នកសម្របសម្រួលសួរសំណួរច្រើន ហើយស្តាប់ច្រើន។
- ដើម្បីសម្របសម្រួលកិច្ចពិភាក្សាមួយ៖
  - ➢ បញ្ចូលអ្នកចូលរួមដែលស្ងាត់ស្ងៀមក្នុងក្រុម
  - ➢ កំណត់ពេលវេលាសម្រាប់អ្នកដែលនិយាយច្រើន
  - ➢ និយាយឡើងវិញ
  - ➢ ស្តាប់
  - ➢ សួរសំណួរឲ្យបានច្រើនអំពីទស្សនៈរបស់យុវជន

## ប័ណ្ណព័ត៌មានលេខ ១៣.ក ដើរតួពិភាក្សា

*(សូមកត់សម្គាល់ថា ប័ណ្ណខ្លះត្រូវបានដាក់បញ្ចូលពីរដង)*

អ្នកគឺជាអ្នកសម្របសម្រួល

អ្នកនិយាយច្រើនពេក ដែលគ្របដណ្តប់លើការពិភាក្សា រហូតដល់អ្នកសម្របសម្រួល

និយាយប្រាប់ដោយពាក្យគួរសមឲ្យអ្នកឈប់។ បន្ទាប់មក ក៏ឈប់និយាយ។

អនុវត្តបែបនេះតែម្តងប៉ុណ្ណោះ។

អ្នកមានការអៀនខ្មាស់។ អ្នកមិននិយាយទេ ប្រសិនបើ ពុំមានការស្នើសុំឲ្យនិយាយ។

អ្នកមានការអៀនខ្មាស់។ អ្នកមិននិយាយទេ ប្រសិនបើ ពុំមានការស្នើសុំឲ្យនិយាយ។

អ្នកនិយាយមិនឈប់ជាមួយអ្នកនៅក្បែរខ្លួន។

អ្នកធ្វើសេចក្តីថ្លែងការណ៍មួយដែលប្រឆាំងទៅនឹងជំនឿរបស់អង្គការទស្សនៈពិភពលោក។ អនុវត្តបែបនេះតែម្តងប៉ុណ្ណោះ។

អ្នកចូលរួមដោយធម្មតាក្នុងការពិភាក្សា។

អ្នកចូលរួមដោយធម្មតាក្នុងការពិភាក្សា។

## ប័ណ្ណព័ត៌មានលេខ ១៣.ខ សម្របសម្រួលការពិភាក្សា

### របៀបសម្របសម្រួលការពិភាក្សា

- **បញ្ចូលអ្នកចូលរួមដែលស្ងាត់ស្ងៀមក្នុងក្រុម៖** សង្កេតមើលក្រុម។ ប្រសិនបើនរណាម្នាក់មិននិយាយទេ សូមសួរពួកគាត់ដោយទន់ភ្លន់ថា តើពួកគាត់មានទស្សនៈយ៉ាងណាដែរ ចំពោះប្រធានបទនេះ។ សូមកុំបង្ខំអ្នកចូលរួមឲ្យនិយាយ ប៉ុន្តែអញ្ជើញពួកគាត់ ប្រសិនបើពួកគាត់ស្ម័គ្រចិត្ត។
- **ដាក់កំណត់លើអ្នកដែលនិយាយច្រើន៖** ប្រសិនបើអ្នកចូលរួមម្នាក់និយាយតែឯងនោះ សូមស្នើសុំដោយគួរសមឲ្យគាត់ផ្តល់ឱកាសដល់អ្នកដទៃផង។ ឧទាហរណ៍ រង់ចាំដល់ពេលអ្នកចូលរួមនោះនិយាយចប់ប្រយោគរបស់គាត់ហើយនិយាយថា**«អរគុណសម្រាប់ការបញ្ចេញមតិ។ សូមទោសដែលបញ្ឈប់អ្នកត្រឹមនេះ ប៉ុន្តែយើងមានពេលវេលាកំណត់។ តើខ្ញុំអាចសួរថាតើមាននរណាផ្សេងទៀតមានយោបល់លើបញ្ហានេះទេ?»**
- **និយាយឡើងវិញ៖** អ្នកអាចជួយឲ្យការពិភាក្សាមានដំណើរការទៅបាន ដោយនិយាយឡើងវិញនូវអ្វី ដែលនរណាម្នាក់ទើបបាននិយាយ ហើយសួរថាតើអ្នកដទៃទៀតយល់ស្រប ឬមិនយល់ស្រប។ ឧទាហរណ៍ **«នាង ទើបនិយាយថា_______________ ។ តើអ្នកយល់ស្របដែរឬទេ?**
- **ស្តាប់៖** ប្រសិនបើអ្នកពិតជាស្តាប់អ្វីដែលយុវជននិយាយពួកគាត់នឹងកាន់តែចង់និយាយ

ថែមទៀត។ អ្នកក៏ អាចគិតនូវសំណួរពាក់ព័ន្ធនានា ដែលអាចជួយដល់ការពិភាក្សា។

- **សួរសំណួរច្រើន៖** សំណួរទាំងនេះ គួរជា**សំណួរអំពីអ្វីដែលយុវជនដទៃទៀតគិត ឬជឿ** មិនមែនគ្រាន់តែជា សំណួរដែលសាកល្បងចំណេះដឹងអំពីការពិតនោះទេ។ ឧទាហរណ៍ នៃសំណួរអំពីអ្វីដែលយុវជនគិត ឬជឿ រួមមាន៖
  - «តើអ្នកគិតថាជាមូលហេតុអ្វីខ្លះដែលធ្វើឲ្យយុវជនចាកចេញពីសាលារៀន?
  - «តើអ្នកគិតថា  អ្នកអាចប្រើប្រាស់បញ្ជីត្រួតពិនិត្យទាំងនេះក្នុងជិវិតផ្ទាល់ខ្លួនអ្នកដែរ ឬទេ? ហេតុអ្វីអាចប្រើប្រាស់បាន ឬ ហេតុអ្វីមិនអាច?

  សំណួរអំពីចំណេះដឹងគឺ៖
  - «ប្រាប់ឈ្មោះប្រទេសមួយដែលជាគោលដៅពេញនិយមសម្រាប់ការជួញដូរ»

# មេរៀនទី១៤៖ របៀបកសាងទំនាក់ទំនងរវាងអ្នកចូលរួមក្លឹប និង ក្លឹប SNYC

## វត្ថុបំណង

អ្នកចូលរួមនឹងយល់ដឹងអំពីរបៀបជំរុញទំនាក់ទំនងរវាងអ្នកចូលរួមក្លឹបនិង ក្លឹប SNYC។

## រយៈពេល

៦០ នាទី

## សម្ភារៈ

- ក្រណាត់មួយផ្ទាំង
- វិញ្ញាបនប័ត្រវគ្គបណ្តុះបណ្តាលអ្នកសម្របសម្រួល ក្លឹប SNYC សម្រាប់អ្នកចូលរួមនីមួយៗ
- បាល់មួយ
- ច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ ១០.ក.ល្បែងពង្រឹងថ្នាក់»
- ច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ ១៤.ក. សំណួរល្បែងបាល់រំលឹកមេរៀន២»

## អ្នកចូលរួម

បុគ្គលិកអង្គការទស្សនៈពិភពលោក ឬ អ្នកសម្របសម្រួលពេញវ័យក្នុងក្លឹប SNYC ដែលបានបញ្ចប់ការបណ្តុះ បណ្តាលអំពីសៀវភៅណែនាំ និងការបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួល។

## អ្នកសម្របសម្រួល

បុគ្គលិកអង្គការទស្សនៈពិភពលោក ឬអ្នកសម្របសម្រួលពេញវ័យ ក្លឹប SNYC ដែលបានសិក្សាចប់ឧបករណ៍នាវិកឆ្លាត និងបានចូលរួមវគ្គបណ្តុះបណ្តាលរបស់អ្នកសម្របសម្រួល

## សកម្មភាពត្រៀមសម្រាប់ចាប់ផ្តើម

ចូរពន្យល់ថា មេរៀននេះនឹងចាប់ផ្តើមជាមួយនឹងល្បែងពង្រឹងថ្នាក់មួយផ្សេងទៀត។

ល្បែងនេះឈ្មោះថា «ល្បែងលាក់ក្រណាត់ ឬលាក់កន្សែង»។ វាគឺជាល្បែងដ៏សប្បាយមួយដែលបង្កើតឲ្យមានការរួបរួមគ្នាក្នុងក្រុម និងជួយសមាជិកក្រុមឲ្យស្គាល់គ្នាទៅវិញទៅមកកាន់តែច្បាស់។

ប្រាប់ឲ្យអ្នកចូលរួមយកច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ១០.ក. ល្បែងពង្រឹងថ្នាក់» ចេញមក។

សូមអនុវត្តតាមសេចក្តីណែនាំដើម្បីលេង «ល្បែងលាក់ក្រណាត់ ឬលាក់កន្សែង» មួយជុំជាមួយអ្នកចូលរួម។ បន្ទាប់មកស្នើឲ្យអ្នកចូលរួមស្ម័គ្រចិត្តក្នុងការសម្របសម្រួលល្បែងនេះ។ ព្យាយាមជ្រើសរើសអ្នកស្ម័គ្រចិត្តដែលពុំធ្លាប់ធ្វើជាអ្នកសម្របសម្រួលនៅក្នុងល្បែងត្រៀមសម្រាប់ចាប់ផ្តើមនៅក្នុងម៉ោងរៀនកន្លងមក។

## សេចក្តីណែនាំ៖ កសាងទំនាក់ទំនង

### កសាងទំនាក់ទំនង

សូមប្រាប់ឲ្យអ្នកចូលរួមបិទភ្នែកមួយនាទី ហើយឲ្យគិតអំពីគ្រូដែលពួកគាត់ចូលចិត្ត។ សូមឲ្យពួកគាត់គិតអំពីចរិកលក្ខណៈរបស់គាត់ ហើយថាហេតុអ្វីបានជាពួកគាត់ចូលចិត្តគ្រូរូបនេះ។ ឥឡូវសួរថាតើអ្នកចូលរួមមានទំនាក់ទំនងល្អជាមួយគ្រូរូបនោះដែរឬទេ ហើយតើអ្វីដែលជួយពួកគាត់ឲ្យរៀនសូត្រពីគ្រូនោះ។ ចូរពន្យល់ថា ការបង្រៀនដែលល្អ មិនត្រឹមតែរួមមានការយល់ច្បាស់ពីប្រធានបទប៉ុណ្ណោះទេប៉ុន្តែត្រូវមានការកសាងទំនាក់ទំនងផងដែរ។ នេះមានន័យថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC គួរព្យាយាមកសាងទំនាក់ទំនងជាមួយអ្នកចូលរួម។ ពួកគាត់គួរព្យាយាមស្វែងរកអ្វីមួយដែលពួកគាត់ចូលចិត្តអំពីសមាជិកគ្រប់គ្នានៃក្លឹប SNYC។ អ្នកសម្របសម្រួលគួរព្យាយាមសិក្សាអំពីគ្រួសាររបស់យុវជនផ្សេងទៀត ចងចាំឈ្មោះមិត្តភ័ក្ររបស់យុវជន ហើយសួរអំពីអ្វីដែលពួកគាត់ចូលចិត្តធ្វើនៅពេលទំនេរ។

### *តាមដានអ្នកចូលរួម ក្លឹប SNYC*

ចូរពន្យល់ថាការងារមួយផ្សេងទៀតរបស់អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC គឺតាមដានយុវជនផ្សេងទៀត។ ឧទាហរណ៍ ប្រសិនបើសមាជិក ក្លឹប SNYC ណាមួយឈប់មកចូលរួមក្លឹបនោះអ្នកសម្របសម្រួលក្លឹបSNYCជាយុវជនគួរសួរមិត្តភ័ក្ររបស់សមាជិកដែលមិនមកនោះថា តើគេសុខទុក្ខជាធម្មតាទេ ?

ប្រាប់អ្នកចូលរួមថា ប្រសិនបើសមាជិកក្លឹប SNYC ណាម្នាក់មានបញ្ហានៅផ្ទះនោះ អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC គួរប្រាប់អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC អំពីបញ្ហានេះ។

ចូរពន្យល់ថា ប្រសិនបើអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ដឹងថាសមាជិកក្លឹប SNYC ណាម្នាក់កំពុងតែគិតចង់ធ្វើចំណាកស្រុក ឬក៏ចាប់ផ្តើមការងារមួយនោះ អ្នកសម្របសម្រួលយុវជន ក្លឹប SNYC គួរប្រាប់អ្នកសម្របសម្រួល ក្លឹប SNYC ពេញវ័យអំពីបញ្ហានេះ។

### *រក្សាសុវត្ថិភាព*

ចូរពន្យល់ប្រាប់ថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC តាមដានអ្នកចូលរួមក្នុង ក្លឹប SNYC ផ្សេងទៀត និងព្យាយាមធ្វើជាមិត្តល្អរបស់ពួកគាត់។ ប៉ុន្តែវាក៏មានសារៈសំខាន់ផងដែរថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ត្រូវគិតជាបឋមអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគាត់ ។ ប្រាប់អ្នកចូលរួមថា អ្នកសម្រមសម្រួលជាយុវជន មិនគួរទៅលេងផ្ទះអ្នកចូលរួម ក្លឹប SNYC ដទៃទៀតទេ (ទាល់តែពួកគាត់គឺជាមិត្តភ័ក្រមុនពេលចូល ក្លឹប SNYC ហើយពួកគេ ដឹងថាផ្ទះនោះគឺជាកន្លែងដែលមានសុវត្ថិភាព)។ ឧទាហរណ៍ ប្រសិនបើអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ម្នាក់ឮថាយុវជនម្នាក់ទៀតត្រូវឳពុកវាយធ្វើបាបនោះ អ្នកសម្របសម្រួលយុវជន ក្លឹប SNYC មិនគួរទៅផ្ទះយុវជននោះទេ ប៉ុន្តែត្រូវផ្តល់ព័ត៌មានដល់អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ជំនួសវិញ។

### យល់ដឹងអំពីដែនកំណត់របស់អ្នក

ចូរពន្យល់ថា អ្នកសម្របសម្រួល ក្លឹប SNYC គួរដឹងអំពីដែនកំណត់របស់ខ្លួនឯង។ នេះមានន័យថា អ្នកសម្របសម្រួលក្លឹប SNYC គួរទទួលស្គាល់ស្ថានភាពដែលពួកគាត់មិនអាចដោះស្រាយបាន។ ប្រាប់អ្នកចូលរួមថា ជួនកាល មធ្យោបាយដែលល្អបំផុតសម្រាប់អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ក្នុងការជួយសមាជិកក្លឹបនោះ គឺប្រាប់ទៅអ្នកសម្របសម្រួលពេញវ័យ។ ក្លឹប SNYC ប្រាប់អ្នកចូលរួមថា នេះគឺជាបញ្ជីនៃស្ថានភាពដែលអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ម្នាក់គួររាយការណ៍ទៅកាន់អ្នកសម្របសម្រួលក្លឹប SNYC ពេញវ័យ។ អានបញ្ជីនេះឲ្យឮៗៈ

- ប្រសិនបើ សមាជិក ក្លឹប SNYC ណាម្នាក់ឈឺ
- ប្រសិនបើ សមាជិក ក្លឹប SNYC ណាម្នាក់គ្មានផ្ទះសម្បែង
- ប្រសិនបើ សមាជិក ក្លឹប SNYC ណាម្នាក់ត្រូវបានវាយធ្វើបាប ឬក៏កំពុងត្រូវបានធ្វើបាបដោយឪពុកម្តាយ
- ប្រសិនបើ សមាជិក ក្លឹប SNYC ណាម្នាក់កំពុងពិចារណាស្វែងរកការងារ ឬកចង់ធ្វើចំណាកស្រុក
- ប្រសិនបើ សមាជិក ក្លឹប SNYC ណាម្នាក់កំពុងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

ចូរពន្យល់ថា ការងារមួយផ្សេងទៀតរបស់អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC គឺជួយអ្នកសម្របសម្រួល ក្លឹប SNYCពេញវ័យ ក្លឹប SNYC ក្នុងការរៀបចំមេរៀន។ អ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC អាចស្នើសុំអ្នកសម្របសម្រួលជាយុវជន ក្លឹប SNYC ឲ្យជួយការងារមួយចំនួន ដូចជារៀបចំសម្ភារៈ ឬក៏រៀបចំបន្ទប់ ក្លឹប SNYC សម្រាប់សិក្សា។

ទោះបីជាយ៉ាងណាក៏ដោយ ចូរពន្យល់ថា អ្នកសម្របសម្រួលពេញវ័យមិនគួរសុំជំនួយពីអ្នកសម្របសម្រួល ក្លឹប SNYCជាយុវជនច្រើនពេកទេ។ ប្រាប់អ្នកចូលរួមថាៈ

- អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC មិនគួរត្រូវបានស្នើសុំឲ្យធ្វើកិច្ចការណាដែលរំខានដល់ការងារសាលារបស់ពួកគាត់ទេ។

- អ្នកសម្របសម្រួលយុវជន ក្លឹប SNYC មិនគួរត្រូវបានស្នើសុំឲ្យធ្វើកិច្ចការណាដែលអាចឲ្យពួកគាត់ប្រឈមនឹងគ្រោះថ្នាក់នោះទេ។ ឧទាហរណ៍ទៅកន្លែងណាដែលពួកគាត់មិនស្គាល់ដើម្បីថតចម្លងឯកសារជាដើម។

ចូរពន្យល់ថា អង្គការទស្សនៈពិភពលោកមានគោលនយោបាយការពារកុមារ ដែលចែងថា យុវជនមិនគួរត្រូវបានទុកឲ្យនៅម្នាក់ឯងជាមួយនឹងមនុស្សពេញវ័យតែឯងនោះទេ។ នេះមានន័យថា អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC មិនគួរត្រូវបានស្នើសុំឲ្យជួយរៀបចំមេរៀន ក្លឹប SNYC ម្នាក់ឯងជាមួយគ្រូម្នាក់នោះទេ។

## សកម្មភាព៖ ល្បែងបាល់រំលឹកមេរៀន

ចូរពន្យល់ថា ឥឡូវក្រុមនឹងលេង «ល្បែងបាល់រំលឹកមេរៀន»។ ប្រាប់អ្នកចូលរួមឲ្យយកច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ ១០.ក. ល្បែងកំដៅសាច់ដុំ ចេញមក ហើយបើកទំព័រដែលមានចំណងជើងថា «ល្បែងបាល់រំលឹកមេរៀន» ម្តងទៀតដើម្បីជួយពួកគាត់ឲ្យចងចាំនូវអ្វីដែលពួកគេបានរៀន។ ដឹកនាំក្រុមឲ្យលេងល្បែងនេះដោយធ្វើតាមសេចក្តីណែនាំ។ ប្រើប្រាស់សំណួរក្នុងច្បាប់ចម្លង «ប័ណ្ណព័ត៌មានលេខ ១៤.ក. សំណួរល្បែងបាល់រំលឹកមេរៀន២» ខាងក្រោម។

ក្រោយពីអ្នកចូលរួមបានឆ្លើយសំណួរប្រមាណជា ៥សំណួរហើយ ត្រូវស្នើសុំអ្នកស្ម័គ្រចិត្តម្នាក់ឲ្យដើរតួនាទីជាអ្នកសម្របសម្រួល។ ទុកឲ្យអ្នកស្ម័គ្រចិត្តរូបនោះដឹកនាំសកម្មភាពពីរសំណួរ បន្ទាប់មកធ្វើការផ្លាស់ប្តូរដើម្បីឲ្យអ្នកផ្សេងទៀតមានឱកាសក្នុងការដឹកនាំ។ បន្តធ្វើសកម្មភាពដូច្នោះរហូតសំណួរទាំងអស់ត្រូវបានឆ្លើយ។

### សង្ខេបមេរៀន

- អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC គួរតាមដានអ្នកចូលរួម ក្លឹប SNYC ដទៃទៀត
- អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYCគួរនៅកន្លែងណាដែលមានសុវត្ថិភាព ហើយមិនត្រូវទៅលេងផ្ទះអ្នកចូលរួមផ្សេងទៀតនោះទេ
- អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYCគួរប្រាប់អ្នកសម្របសម្រួលពេញវ័យ ប្រសិនបើអ្នកចូលរួម ក្លឹប SNYC ផ្សេងទៀតស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ឈឺ ឬមានបំណងធ្វើទេសន្តប្រវេសន៍
- អ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC អាចជួយរៀបចំមេរៀនអ្នកសម្របសម្រួលជាមនុស្សពេញវ័យក្នុងក្លឹប SNYC ដរាបណាវាមិនប៉ះពាល់ដល់កិច្ចការសាលា ឬប្រឈមនឹងភាពគ្រោះថ្នាក់
- យោងទៅតាមគោលនយោបាយការពារកុមារ អ្នកសម្របសម្រួល ក្លឹប SNYC យុវជនមិនត្រូវនៅក្នុងបន្ទប់តែម្នាក់ឯងជាមួយនឹងអ្នកសម្របសម្រួល ក្លឹប SNYC ពេញវ័យ នោះទេ

## ការបិទបញ្ចប់

ចូរពន្យល់ថា ការធ្វើជាអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ទទួលបានផលប្រយោជន៍ច្រើន។ វាអាចជួយឲ្យពួកគេកសាងជំនាញ និងទទួលបានបទពិសោធន៍ដែលអាចមានប្រយោជន៍ក្នុងពេលអនាគត។

ចូរពន្យល់ថា ប្រសិនបើអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC ចូលរួមគ្រប់មេរៀននោះ ពួកគាត់នឹងទទួលបានរង្វាន់លើកទឹកចិត្តកម្រិត៣ ហើយនឹងមានសិទ្ធិដាក់ពាក្យសុំធ្វើជាអ្នកសម្របសម្រួលក្លឹប SNYC ពេញវ័យនៅពេលអនាគត។

រំលឹកដល់យុវជនថា ក្លឹប SNYC គឺជាទីកន្លែងដ៏ល្អប្រសើរមួយដើម្បីជួបជុំមិត្តភ័ក្រ និងរៀនពីជំនាញនានាដែលអាចជួយពួកគាត់ក្នុងការការពារខ្លួន។

ជាចុងក្រោយប្រាប់យុវជនថាពួកគាត់ត្រូវបានផ្តល់ឱកាសមួយធ្វើជាអ្នកដឹកនាំសហគមន៍របស់ពួកគាត់ ហើយថាអង្គការទស្សនៈពិភពលោក និងអ្នកសម្របសម្រួល ក្លឹប SNYC រង់ចាំមើលនូវសកម្មភាពល្អៗដែលពួកគាត់នឹងអនុវត្ត។

អរគុណអ្នកចូលរួមទាំងអស់ដែលបានចូលរួម។

ចែកលិខិតបញ្ជាក់ការសិក្សា

## ប័ណ្ណព័ត៌មានលេខ ១៤ .ក. សំណួរល្បែងបាល់រំលឹកមេរៀន២

១. តើអ្វីគឺជា ក្លឹប SNYC?

២. តើអ្វីគឺជាអ្នកសម្របសម្រួល?

៣. តើអ្វីគឺឧបករណ៍នារីកវៃឆ្លាត?

៤. តើអ្វីគឺជា ប័ណ្ណព័ត៌មានលេខ?

៥. តើអ្វីគឺជាកូនឧបករណ៍នារីកវៃឆ្លាត?

៦. តើអ្វីគឺជាមេរៀន?

៧. តើមេរៀនមួយមានរយៈពេលប៉ុន្មាន?

៨. តើអ្វីគឺជាការជួញដូរមនុស្ស?

៩. តើអ្វីគឺជាការធ្វើចំណាកស្រុក?

១០. តើយុវជននឹងយល់ដឹងអំពីអ្វីនៅ ក្លឹប SNYC?

១១. តើអ្វីខ្លះជាជំនាញជីវិត?

១២. តើអ្នកទទួលបានអ្វីនៅពេលចូលសិក្សាមេរៀន?

១៣. តើមានប៉ុន្មានមេរៀនដែលអ្នកត្រូវចូលរួមដើម្បីទទួលបានរង្វាន់កម្រិត ៣?

***ចម្លើយចំពោះសំណួរទី១ ដល់ទី១៣ មាននៅក្នុងមេរៀនទី១។***

១៤. តើជំនាញអ្វីខ្លះដែលអ្នកអាចប្រើប្រាស់ដើម្បីសម្របសម្រួលការពិភាក្សាមួយ?

***ចម្លើយៈ***

- បញ្ចូលយុវជនដែលស្ងាត់ស្ងៀមក្នុងក្រុម
- និយាយឡើងវិញ
- កំណត់ពេលសម្រាប់អ្នកនិយាយច្រើន
- ស្តាប់
- សួរសំណួរឲ្យបានច្រើន

១៥. តើអ្នកសម្របសម្រួលជាយុវជនក្នុងក្លឹប SNYC អាចជួយអ្នកចូលរួមដែលមិនចេះអាន បានយ៉ាងដូចម្តេច?

***ចម្លើយៈ***

- អង្គុយជិតពួកគាត់ ហើយអានផ្ទាំងគំនូសបង្ហាញដែលបត់បានឲ្យឮៗ
- ចាប់ដៃគូជាមួយពួកគាត់ពេលណាដែលក្រុមត្រូវបានបំបែកជាក្រុមតូចៗ
- ចូលរួមជាមួយពួកគាត់នៅក្នុងការពិភាក្សាតាមក្រុមតូចៗ

- ប្រព្រឹត្តទៅលើពួកគាត់ដោយការគោរព
- កុំប្រាប់យុវជនផ្សេងទៀតថា ពួកគាត់មិនចេះអាន

១៦. ប្រសិនបើសមាជិក ក្លឹប SNYC ម្នាក់ឈប់មករៀន តើអ្នកគួរធ្វើអ្វី?

***ចម្លើយៈ***

- សួរមិត្តភ័ក្ររបស់សមាជិករូបនោះថា ហេតុអ្វីបានជាគេឈប់មករៀន ហើយប្រាប់ព័ត៌មាននេះទៅអ្នកសម្របសម្រួលពេញវ័យ។

ប្រសិនបើ សមាជិក ក្លឹប SNYC ម្នាក់នោះឈប់មករៀនដោយសារតែឪពុកម្តាយវាយធ្វើបាបនោះ តើអ្នកគួរទៅផ្ទះសមាជិកនោះឬអត់?

***ចម្លើយៈ***

- មិនត្រូវទៅទេ អ្នកគួរប្រាប់រឿងនេះទៅកាន់អ្នកសម្របសម្រួលពេញវ័យ

១៧. ប្រសិនបើអ្នកដឹងថា សមាជិក ក្លឹប SNYC ម្នាក់ឈឺនោះ តើអ្នកគួរធ្វើអ្វី?

***ចម្លើយៈ***

- ប្រាប់ព័ត៌មានទៅកាន់អ្នកសម្របសម្រួលពេញវ័យ

១៨. ប្រសិនបើមិត្តម្នាក់នៅក្នុង ក្លឹប SNYC ប្រាប់អ្នកថា គេកំពុងមានផែនការធ្វើចំណាកស្រុកនោះ តើអ្នកគួរធ្វើអ្វី?

***ចម្លើយៈ***

- ប្រាប់ព័ត៌មានទៅកាន់អ្នកសម្របសម្រួលពេញវ័យ

**អង្គការទស្សនៈពិភពលោកអន្តរជាតិ**

ការិយាល័យប្រចាំតំបន់អាស៊ីខាងកើត

អាសយដ្ឋាន៖ អគារមជ្ឈមណ្ឌលពាណិជ្ជកម្ម Bangkok ជាន់ទី១៣

២៩ Sukhumvit 63 ( ផ្លូវ Ekamai ) Klongton Nua

Wattana Bangkok 10110 ប្រទេសថៃ

ទូរស័ព្ទ៖ +66-2-3916155; +66-2-3818861

ទូរសារ៖ +66-2-3811976

គេហទំព័រ ៖ http://www.wvi.org/asiapacifc